# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ










# គោលនយោបាយស្តីពី ការអភិវឌ្ឍការស្រាវជ្រាវ និង នវានុវត្តន៍

## ២០២០ - ២០២៤



ការកែសម្រួលច្បាប់ចម្លងជាភាសាអង់គ្លេសដោយ **Mr. ROSS Simon**

រចនាទំព័រដោយ **លោក សុផល រតនៈ**

រូបថតដោយ **លោក សុផល រតនៈ** និង **បណ្ឌិត សុខ សិរី**

បោះពុម្ពនៅ ភ្នំពេញ កម្ពុជា

# មាតិកា


**ជំពូក១ : បុព្វកថា** ៧

១.១ សារតា ៧

១.២. ចក្ខុវិស័យ ៨

១.៣. គោលដៅ ៨

១.៤. បេសកកម្ម ៩

១.៥. វិធីសាស្រ្ត ៩

១.៦. យុទ្ធសាស្រ្ត ៩

**ជំពូក២ : គុណភាពស្រាវជ្រាវនិងកម្មសិទ្ធបញ្ញា** ១៤

២.១. ស្នាដៃស្រាវជ្រាវ ផលប្រយោជន៍នៃស្នាដៃស្រាវជ្រាវ និងផលជះនៃស្នាដៃស្រាវជ្រាវ ១៤

២.២. គុណភាពនៃការស្រាវជ្រាវ ១៥

២.៣. កម្មសិទ្ធបញ្ញា ១៨

**ជំពូក៣ : ការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវ កម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រនិងក្រោយបណ្ឌិត** ២១

៣.១. ប្រភេទហិរញ្ញប្បទាន ២១

៣.២. សេវាផ្តល់ប្រឹក្សាយោបល់ ២២

៣.៣. ការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវ ស.ភ.ភ.ព. ២២

៣.៤. តួនាទីនិងទំនួលខុសត្រូវ ២៣

៣.៥. កម្មវិធីស្រាវជ្រាវរបស់និស្សិត ២៤

៣.៦. កម្មវិធីក្រោយបណ្ឌិត ២៥

**ជំពូក៤ : តំណែងស្រាវជ្រាវ និងកម្មវិធីលើកទឹកចិត្តអ្នកស្រាវជ្រាវ** ២៨

៤.១. តំណែងស្រាវជ្រាវ ២៨

៤.២. ការលើកទឹកចិត្ត ២៩

# ឯកឧត្តមបណ្ឌិត មុី កល្យាណ



## សារពីប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលមានវ័យចំណាស់ជាងគេនិងឈានមុខគេនៅកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.) ខិតខំលើកកម្ពស់គុណភាពនៃការបង្រៀននិងការស្រាវជ្រាវដើម្បីបម្រើសហគមន៍។ ចក្ខុវិស័យរបស់ស.ភ.ភ.ព. គឺធ្វើខ្លួនឱ្យក្លាយជាសាកលវិទ្យាល័យឈានមុខគេនៅកម្ពុជាក្នុងការបង្រៀននិងរៀន ការស្រាវជ្រាវនិងនវានុវត្តន៍ និងការចូលរួមក្នុងសង្គម។ បច្ចុប្បន្ន ស.ភ.ភ.ព. កំពុងចូលរួមក្នុងសកម្មភាពនានានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក ដើម្បីឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គ្រឹះស្ថានរបស់យើងមានបំណងលើកស្ទួយសម្បត្តិវប្បធម៌ជាតិ និងបេតិកភណ្ឌធម្មជាតិរបស់កម្ពុជាតាមរយៈការផ្ដល់ចំណេះដឹងប្រកបដោយគុណភាពខ្ពស់ផ្នែកស្រាវជ្រាវនិងនវានុវត្តន៍ដែលអាចចូលរួមយ៉ាងសកម្មក្នុងសង្គម។

ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមនៅកម្ពុជា រាជរដ្ឋាភិបាលបាននិង កំពុងលើកកម្ពស់វិស័យអប់រំលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ យើងមានទិសដៅផលិតអ្នកបង្កើតថ្មីជំនាន់ក្រោយដែលមានចំណេះដឹងរឹងមាំផ្នែកវិទ្យាសាស្ត្រ និងបំណិនត្រិះរិះសព្វជ្រុងជ្រោយ។ ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងនវានុវត្តន៍គឺជាយន្តការសមស្របបំផុតសម្រាប់គាំទ្រការបង្កើតផលិតផលថ្មីៗនិងដំណើរការនានាដែលមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចជាតិក្នុងការឈានទៅរកយុគសម័យបដិវត្តឧស្សាហកម្មទីបួន។

ការធ្វើឱ្យស.ភ.ភ.ព. ក្លាយជាសាកលវិទ្យាល័យស្រាវជ្រាវនឹងជួយប្រែក្លាយខឿនសេដ្ឋកិច្ចកម្ពុជា ពីការពឹងផ្អែកលើកម្លាំងពលកម្មគ្មានជំនាញទៅជាការជំរុញដោយជំនាញឧស្សាហកម្ម។ ចក្ខុវិស័យនេះស្របតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។

តំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមប្ដេជ្ញាគាំទ្រការអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយស.ភ.ភ.ព. ស្ដីពីការអភិវឌ្ឍការស្រាវជ្រាវនិងនវានុវត្តន៍។ ពេលវេលាសម្រាប់ការវិនិយោគក្នុងការបង្កើតសាកលវិទ្យាល័យស្រាវជ្រាវនៅកម្ពុជាបានមកដល់ហើយ។ ស.ភ.ភ.ព. មិនត្រូវពឹងផ្អែកតែលើស្មារតីស្ម័គ្រចិត្តនិងការតាំងចិត្តរបស់អ្នកស្រាវជ្រាវម្នាក់ៗដើម្បីធ្វើការស្រាវជ្រាវប្រកបដោយគុណភាពតទៅទៀតទេ។ គោលនយោបាយនេះនឹងនាំមកនូវការស្រាវជ្រាវទាំងផ្នែកចំណេះដឹង ទាំងផ្នែកអនុវត្ត និងទាំងការអភិវឌ្ឍដោយចីរភាពដល់គ្រឹះស្ថានសិក្សានេះដែលមានសារៈសំខាន់ជាពិសេសចំពោះការអភិវឌ្ឍកម្មវិធីសិក្សា ក៏ដូចជា លំហូរចំណេះដឹង ការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងកិច្ចពិភាក្សាសង្គម ដែលជាតម្រូវការចាំបាច់ដើម្បីសម្រេចនូវចក្ខុវិស័យអភិវឌ្ឍន៍របស់កម្ពុជា។ ខ្ញុំជឿជាក់ថាគោលនយោបាយនេះនឹងជួយឱ្យស.ភ.ភ.ព. ក្លាយជាសាកលវិទ្យាល័យជាតិសម្រាប់ការស្រាវជ្រាវថ្នាក់តំបន់និងអន្តរជាតិ ដែលប្រទេសកម្ពុជាកំពុងត្រូវការ។

# ឯកឧត្តមបណ្ឌិត ជេត ជាលី



## សារពីសាកលវិទ្យាធិការនៃសាកលវិទ្យាភូមិន្ទភ្នំពេញ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.) បានប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបង្ហាញសមត្ថភាពរបស់ខ្លួនក្នុងការស្រាវជ្រាវផ្នែកអនុវត្តដ៏ល្អបំផុត និងការចូលរួមក្នុងសង្គមក្នុងវិស័យឧត្តមសិក្សានៅកម្ពុជា។ ព្រោះហេតុនេះហើយទើប សភភព. ត្រូវបានទទួលស្គាល់ដោយស្ថាប័នជាតិនិងអន្តរជាតិថាជាគ្រឹះស្ថានជាតិនាំមុខគេក្នុងវិស័យស្រាវជ្រាវ។ សភភព. ស្ថិតក្នុងចំណោមសាកលវិទ្យាល័យសាធារណៈមួយចំនួនតូចនៅកម្ពុជា ដែលបានបង្កើតហិរញ្ញប្បទានស្រាវជ្រាវសម្រាប់លើកស្ទួយសកម្មភាពស្រាវជ្រាវរបស់បុគ្គលិកអប់រំ។ ប្រការនេះបានបង្ហាញពីជោគជ័យក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់ការស្រាវជ្រាវ ដែលស្តែងចេញតាមរយៈស្នាដៃស្រាវជ្រាវសំខាន់ៗសម្រាប់បោះពុម្ពផ្សាយ។ ឧទាហរណ៍ សន្ទស្សន៍ដកស្រង់ (Citation Index) របស់ទស្សនាវដ្តី Scopus បានបង្ហាញថា នៅកម្ពុជា មានតែសាកលវិទ្យាល័យភូមិន្ទភ្នំពេញមួយប៉ុណ្ណោះ ដែលមានអ្នកនិពន្ធមានស្នាដៃស្រាវជ្រាវស្ថិតក្នុងលំដាប់កំពូលអត្ថបទទាំង១០ក្នុង Scopus ដែលជាទស្សនាវដ្តីដ៏ល្អមួយ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញស្ថិតក្នុងចំណោមសាកលវិទ្យាល័យសាធារណៈមួយចំនួនតូចនៅកម្ពុជាដែលមានសមត្ថភាពផលិតស្នាដៃស្រាវជ្រាវប្រកបដោយគុណភាព។ ផែនការយុទ្ធសាស្ត្ររបស់ស.ភ.ភ.ព. ឆ្នាំ២០១៩-២០២៣ ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹង និងដើម្បីការអនុវត្ត ទាំងផ្នែក STEM និងទាំងផ្នែកវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ។ ផែនការយុទ្ធសាស្ត្រនេះមានបេសកកម្មមួយគឺប្រែក្លាយស.ភ.ភ.ព. ឱ្យទៅជាកន្លែងដែលអ្នកស្រាវជ្រាវអាចទទួលបានធនធាន និងអាចបង្កើតក្រុមការងារដើម្បីធ្វើការស្រាវជ្រាវជាមានលក្ខណៈវិទ្យាសាស្ត្រ។ លទ្ធផលនៃបេសកកម្មនេះស្តែងចេញតាមរយៈការដកស្រង់ដោយស្ថាប័នដែលពាក់ព័ន្ធនឹងស.ភ.ភ.ព. ចេញពីមូលដ្ឋានទិន្នន័យដែលពាក់ព័ន្ធនិងការចូលរួមបង្កើតមជ្ឈមណ្ឌលអន្តរគ្រឹះស្ថាននានាសម្រាប់ការស្រាវជ្រាវពហុវិស័យ។ ដើម្បីជាចំណែកក្នុងការលើកស្ទួយវប្បធម៌ស្រាវជ្រាវ មកទល់ពេលនេះ ស.ភ.ភ.ព. បង្កើតបានទស្សនាវដ្តីស្រាវជ្រាវមួយចំនួន។ ទស្សនាវដ្តីទាំងនេះបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវទាំងផ្នែកពង្រីកចំណេះដឹង និងទាំងផ្នែកអនុវត្ត ទាំងក្នុងនិងក្រៅប្រទេស ដែលរួមចំណែកដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបរិស្ថាន ទាំងក្នុងប្រទេស និងក្នុងតំបន់។

ខ្ញុំជឿជាក់ថា គោលនយោបាយស្តីពីការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍នេះ នឹងមានសារៈសំខាន់ក្នុងការប្រែក្លាយ ស.ភ.ភ.ព. ឱ្យទៅជាសាកលវិទ្យាល័យស្រាវជ្រាវមួយ។ គោលនយោបាយនេះបង្ហាញពីរបៀបដែល ស.ភ.ភ.ព. រៀបចំផែនការសម្រាប់គ្រប់គ្រងហិរញ្ញប្បទាននិងការបោះពុម្ព ព្រមទាំងរបៀបធ្វើជាមជ្ឈមណ្ឌលចំណេះដឹងផងដែរ។ គោលនយោបាយនេះក៏មានសារៈសំខាន់ផងដែរក្នុងការជួយឱ្យដៃគូរបស់យើង ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត (ស៊ីដា) អាចមើលឃើញយ៉ាងច្បាស់នូវវិធីសាស្ត្ររបស់យើងក្នុងការអភិវឌ្ឍការស្រាវជ្រាវ និងនវានុវត្តន៍។

# ចលករគន្លឹះ



គណៈកម្មការគ្រប់គ្រងការងារស្រាវជ្រាវស.ភ.ភ.ព. និងអនុគណៈកម្មការនានា
វិស័យស្រាវជ្រាវជាអាទិភាព
ការអភិវឌ្ឍសមត្ថភាព
និងហិរញ្ញប្បទានស្រាវជ្រាវ
ការស្រាវជ្រាវសហការ
និងសហប្រតិបត្តិការអន្តរជាតិ
សេវាកម្មស្រាវជ្រាវ
និងប្រឹក្សាយោបល់
ការលើកទឹកចិត្តស្រាវជ្រាវតាមវិធីច្នៃប្រឌិត
ការបោះពុម្ពផ្សាយ
និងការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ
បង្កើនការគាំទ្រដល់ការស្រាវជ្រាវ
ពង្រីកចំណេះដឹងនិងការស្រាវជ្រាវអនុវត្ត
ការផ្តល់មូលនិធិស្រាវជ្រាវ
ការសម្របសម្រួលការស្រាវជ្រាវ
Key Strategies

# ជំពូក ១ បុព្វកថា

## ១.១ សាវតា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈធំជាងគេនៅកម្ពុជា ដែលមាននិស្សិតអាហារូបករណ៍និងបង់ថ្លៃ ទាំងកម្មវិធីថ្នាក់បរិញ្ញាបត្រនិងក្រោយបរិញ្ញាបត្រ សរុបចំនួន ១២.០០០នាក់។ សាកលវិទ្យាល័យនេះគឺជាសមាជិកពេញសិទ្ធនៃបណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN) និងមានចក្ខុវិស័យ “ធ្វើខ្លួនឱ្យក្លាយជាសាកលវិទ្យាល័យឈានមុខគេនៅកម្ពុជា ប្រកបដោយកិត្តិនាមថ្នាក់តំបន់ ក្នុងការរៀននិងបង្រៀន ការស្រាវជ្រាវនិងនវានុវត្តន៍ ព្រមទាំងការចូលរួមសកម្មភាពសង្គម”។ ផែនការយុទ្ធសាស្ត្របច្ចុប្បន្នរបស់គ្រឹះស្ថានបានកំណត់យកជាអាទិភាពនូវការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវដ៏ខ្លាំងក្លាដើម្បីបោះពុម្ពផ្សាយដែលមានការត្រួតពិនិត្យពីក្រុមអ្នកវិទ្យាសាស្ត្រ និងការផ្សារភ្ជាប់ទៅនឹងបណ្តាញឧស្សាហកម្មនិងសហគមន៍។ ផែនការយុទ្ធសាស្ត្រនេះមានភាពស៊ីសង្វាក់គ្នាជាមួយផែនការយុទ្ធសាស្ត្រជាតិស្តីពីការអប់រំជាតិ (NESP) ២០១៤-២០១៨ ដែលមានគោលបំណងគាំទ្រដល់ការផ្លាស់ប្តូរប្រទេសដែលមានប្រាក់ចំណូលពីមធ្យមកម្រិតទាបទៅមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទទួលបានឋានៈជាប្រទេសអភិវឌ្ឍហើយនៅឆ្នាំ២០៥០។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា លើកកម្ពស់ការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រក្នុងយុទ្ធសាស្ត្រអប់រំឧត្តមសិក្សាថ្នាក់ជាតិ។ ឧទាហរណ៍ ក្នុងគោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រគន្លឹះទាំង៨គឺ “ធានាថាបុគ្គលិកអប់រំនិងនិស្សិតស.ភ.ភ.ព. ជាពិសេស និស្សិតថ្នាក់ក្រោយឧត្តម រួមចំណែកលើកស្ទួយវប្បធម៌ស្រាវជ្រាវនិងអភិវឌ្ឍន៍នៅកម្ពុជា ដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍ជាតិ”។ ការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រត្រូវបានចាត់ទុកជាកិច្ចការសំខាន់បំផុតក្នុងការលើកកម្ពស់គោលនយោបាយឧស្សាហកម្ម ៤.០ របស់កម្ពុជា។ គោលនយោបាយ៤.០នេះមានបំណងបង្កើតការច្នៃប្រឌិតនិងនវានុវត្តន៍ដែលជាតម្រូវការចាំបាច់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម។

បច្ចុប្បន្ន ការបោះពុម្ពស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្ររបស់បុគ្គលិកស្រាវជ្រាវនៅស.ភ.ភ.ព. ត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គល ដោយសារមានចំណង់ចំណូលចិត្តនិងទទួលបានអត្ថប្រយោជន៍ផ្ទាល់ខ្លួន ព្រមទាំងមានសមត្ថភាពក្នុងការស្វែងរកធនធានពីខាងក្រៅសម្រាប់ការស្រាវជ្រាវ។ ទាំងនៅថ្នាក់គ្រឹះស្ថាន និងទាំងនៅថ្នាក់ជាតិ យន្តការដែលមានស្រាប់សម្រាប់ជំរុញការអភិវឌ្ឍវប្បធម៌ស្រាវជ្រាវមានតិចតួចប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ស.ភ.ភ.ព. ត្រូវបានស្ថាប័នពាក់ព័ន្ធនានារបស់រដ្ឋាភិបាលនិងស្ថាប័នហិរញ្ញវត្ថុ

អន្តរជាតិដូចជាធនាគារពិភពលោកជាដើម ជ្រើសរើសយកធ្វើជាគ្រឹះស្ថានឧត្តមសិក្សាគម្រូដែលមានការអនុវត្តការស្រាវជ្រាវល្អបំផុតនៅកម្ពុជា។ កិត្តិយសនេះគឺជាលទ្ធផលនៃការខិតខំយ៉ាងខ្លាំងរបស់សាស្ត្រាចារ្យ ស.ភ.ភ.ព. ក្នុងការលើកកម្ពស់ការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ។

ស.ភ.ភ.ព. ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាគ្រឹះស្ថានឧត្តមសិក្សាជាតិឈានមុខគេផ្នែកលទ្ធផលស្រាវជ្រាវ។ ឧទាហរណ៍ ការស្វែងរកមួយរបស់ Scopus បានបង្ហាញថា ស.ភ.ភ.ព. ជាគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាតែមួយគត់ដែលស្ថិតក្នុងលំដាប់កំពូលទាំង១០ ដែលមានអត្ថបទស្រាវជ្រាវបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីអន្តរជាតិដែលមានការត្រួតពិនិត្យត្រឹមត្រូវពីក្រុមអ្នកវិទ្យាសាស្ត្រ។ ទោះបីជាយ៉ាងនេះក្តី ក្នុងនាមជាគ្រឹះស្ថានស្រាវជ្រាវឈានមុខគេ ប្រសិនបើ ស.ភ.ភ.ព. មានបំណងចង់បាននូវចំណាត់ថ្នាក់សាកលវិទ្យាល័យពិភពលោកនោះ ការវិនិយោគទ្រទ្រង់ទ្រទ្រាយធំលើសមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានគឺជាតម្រូវការចាំបាច់។ ប្រសិនបើបំណងនេះបានសម្រេចមែន វានឹងបង្ហាញយ៉ាងច្បាស់ថាប្រទេសកម្ពុជាមានសមត្ថភាពកាន់តែប្រសើរក្នុងការបង្កើតចំណេះដឹងក្នុងស្រុកនិងនវានុវត្តន៍ក្នុងប្រទេស និងក្នុងការដោះស្រាយដោយឯករាជ្យនូវបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការធ្វើឲ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមមានលទ្ធផលកាន់តែល្អប្រសើរ។

នៅឆ្នាំ២០១៧ ស.ភ.ភ.ព. បានបង្កើតកញ្ចប់ថវិកាមួយហៅថា "ហិរញ្ញប្បទានស្រាវជ្រាវស.ភ.ភ.ព." សម្រាប់លើកស្ទួយវប្បធម៌ស្រាវជ្រាវនៅស.ភ.ភ.ព. និងដើម្បីលើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យបោះពុម្ពស្នាដៃស្រាវជ្រាវរបស់ខ្លួនក្នុងទស្សនាវដ្តីដែលមានការត្រួតពិនិត្យត្រឹមត្រូវពីអ្នកវិទ្យាសាស្ត្រ។ ដើម្បីជំរុញការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវឱ្យកើតមានឡើង ស.ភ.ភ.ព. ក៏បានបង្កើតផងដែរនូវទស្សនាវដ្តីស្រាវជ្រាវដែលមានការត្រួតពិនិត្យត្រឹមត្រូវពីអ្នកវិទ្យាសាស្ត្រ។ ទស្សនាវដ្តីទាំងនោះរួមមាន៖ "Cambodian Journal of Natural History", "Insight: Cambodia Journal of Basic and Applied Research, Cambodian Review of Language Learning and Teaching", និង "Cambodian Communication Review of EFL Research"។

## ១.២. ចក្ខុវិស័យ

ស.ភ.ភ.ព. គឺជាសាកលវិទ្យាល័យឈានមុខរបស់កម្ពុជាខាងក្នុងវិស័យស្រាវជ្រាវផ្នែកទ្រឹស្តី និងផ្នែកអនុវត្ត។

## ១.៣. គោលដៅ

- **គោលដៅទី១** : ដើម្បីកសាងប្រព័ន្ធធានាគុណភាពស្រាវជ្រាវនិងការពារកម្មសិទ្ធបញ្ញា

- **គោលដៅទី២** : ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ និងធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវមានភាពជឿនលឿន សម្រាប់កម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រ និងក្រោយបណ្ឌិត នៅតាមមហាវិទ្យាល័យនីមួយៗ។
- **គោលដៅទី៣** : ដើម្បីអនុវត្តគោលការណ៍សម្រាប់អ្នកស្រាវជ្រាវសុទ្ធសាធ និងកម្មវិធីលើកទឹកចិត្តដ៏ទៃទៀតសម្រាប់បុគ្គលិកអប់រំដែលមានស្នាដៃឆ្នើមខាងស្រាវជ្រាវ និងនវានុវត្តន៍។

## ១.៤. បេសកកម្ម

ដើម្បីបង្កើតវប្បធម៌ស្រាវជ្រាវច្នៃប្រឌិតនិងនវានុវត្តន៍តាមរយៈ៖

- ការអនុវត្តគោលការណ៍ផ្តល់គ្រឿងលើកទឹកចិត្តដល់បុគ្គលិកស្រាវជ្រាវដែលបានបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ ឬផលិតប៉ាតង់ដែលមានអាជ្ញាប័ណ្ណ។
- ការវិនិយោគរយៈពេលយូរលើការកសាងចំណេះដឹង បំណិន និងសមត្ថភាពខាងផ្នែកស្រាវជ្រាវឱ្យកាន់តែប្រសើរជូនបុគ្គលិកអប់រំ តាមរយៈការបណ្តុះបណ្តាល ការណែនាំ និងការផ្តល់ប្រឹក្សាយោបល់។
- ការបង្កើតភាពជាដៃគូសហការស្រាវជ្រាវ ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ដែលជួយគាំទ្រដល់បុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. តាមរយៈហិរញ្ញប្បទាន និងកម្មវិធីផ្លាស់ប្តូរនានា។

## ១.៥. វិធីសាស្ត្រ

ក្នុងរយៈពេល៥ឆ្នាំដំបូង គោលនយោបាយស.ភ.ភ.ព. ស្តីពីការអភិវឌ្ឍការស្រាវជ្រាវនិងនវានុវត្តន៍ផ្តោតលើតែដំណាក់កាលទី១ និងទី២ប៉ុណ្ណោះ។

- ជំហានទី១ : បណ្តុះវប្បធម៌ស្រាវជ្រាវនិងកៀរគរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស។
- ជំហានទី២ : ធ្វើឱ្យការស្រាវជ្រាវមានភាពរលូននិងជឿនលឿន។
- ជំហានទី៣ : ធ្វើឱ្យការស្រាវជ្រាវតាមវិស័យនានាមានភាពស្រួចស្រាវនិងស៊ីជម្រៅ។

## ១.៦. យុទ្ធសាស្ត្រ

| ១.0 | **គណៈកម្មការគ្រប់គ្រងការងារស្រាវជ្រាវ ស.ភ.ភ.ព. និងអនុគណៈកម្មការនានា** |
|---|---|
| ១.១ | ពង្រឹងមុខងារគណៈកម្មការគ្រប់គ្រងការងារស្រាវជ្រាវស.ភ.ភ.ព. ដើម្បី៖ (១) អនុវត្តនីតិវិធីក្រមសីលធម៌មនុស្សសម្រាប់ការស្រាវជ្រាវ (២) ជួយបុគ្គលិកអប់រំផ្នែកបច្ចេកទេសក្នុងការធ្វើសំណើរស្រាវជ្រាវឱ្យត្រូវនឹងអាទិភាពរបស់ស.ភ.ភ.ព. (៣) បង្កើតទស្សនាវដ្តីស្រាវជ្រាវ |

| | |
|---|---|
| | ដែលមានការត្រួតពិនិត្យដោយក្រុមអ្នកវិទ្យាសាស្ត្រដើម្បីជួយអ្នកស្រាវជ្រាវឱ្យបោះពុម្ពស្នាដៃស្រាវជ្រាវរបស់ខ្លួន និង (៤) ផ្តល់អនុសាសន៍និងជំនួយបច្ចេកទេសដល់ការិយាល័យស្រាវជ្រាវនិងអនុគណៈកម្មការនានាក្នុងការដោះស្រាយបញ្ហាផ្សេងៗទាក់ទងនឹងការងារស្រាវជ្រាវ។ |
| ១.២ | បង្កើតអនុគណៈកម្មការសម្រាប់ក្រុមសីលធម៌ស្រាវជ្រាវមនុស្សនិងសត្វសម្រាប់ពិនិត្យសំណើស្រាវជ្រាវនានា និងធានានូវសេចក្តីថ្លៃថ្នូរ សិទ្ធិ សុវត្ថិភាព និងសុខុមាលភាពរបស់អ្នកចូលរួមស្រាវជ្រាវអំពីមនុស្សនិងសត្វ។ |
| ១.៣ | បង្កើតអនុគណៈកម្មការដើម្បីត្រួតពិនិត្យ ប្រឹក្សាយោបល់ និងផ្តល់ជំនួយបច្ចេកទេសដល់បុគ្គលិកអប់រំក្នុងការអភិវឌ្ឍនិងអនុវត្តគម្រោងស្រាវជ្រាវ។ |
| ១.៤ | បង្កើតអនុគណៈកម្មការទទួលបន្ទុកគ្រប់គ្រងការបោះពុម្ពឯកសារសិក្សានិងស្រាវជ្រាវដើម្បីលើកស្ទួយការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្តីដែលមានការត្រួតពិនិត្យពីក្រុមអ្នកវិទ្យាសាស្ត្រ និងផ្តល់សេវាសន្ទស្សន៍និងសង្ខិតន័យ។ |
| **២.០** | **វិស័យស្រាវជ្រាវជាអាទិភាព** |
| ២.១ | កំណត់វិស័យស្រាវជ្រាវជាអាទិភាពសំដៅពង្រីកចំណេះដឹងដែលជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងផែនការសកម្មភាពរយៈពេល៥ឆ្នាំ។ វិស័យស្រាវជ្រាវជាអាទិភាពទាំងនេះត្រូវឆ្លើយតបទៅនឹងបញ្ហាធំៗរបស់ជាតិ។ |
| ២.២ | ភ្ជាប់លទ្ធផលស្រាវជ្រាវទៅនឹងការអនុវត្តជាក់ស្តែងដោយបញ្ចូលទ្រឹស្តីនិងទស្សនទានទាំងនេះទៅក្នុងគោលនយោបាយនិងកម្មវិធីសិក្សា។ |
| **៣.០** | **ការអភិវឌ្ឍសមត្ថភាពនិងហិរញ្ញប្បទានស្រាវជ្រាវ** |
| ៣.១ | អភិវឌ្ឍសមត្ថភាពស្រាវជ្រាវជូនដល់បុគ្គលិកនិងនិស្សិត តាមរយៈសិក្ខាសាលានិងការបណ្តុះបណ្តាលអាស្រ័យលើតម្រូវការជាក់ស្តែង។ |
| ៣.២ | ផ្តល់ហិរញ្ញប្បទានស្រាវជ្រាវដល់បុគ្គលិកអប់រំស.ភ.ភ.ព. ដើម្បីធ្វើសកម្មភាពស្រាវជ្រាវ ចូលរួមសន្និសីទនានា និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ |
| ៣.៣ | លើកទឹកចិត្តបុគ្គលិកស្រាវជ្រាវដោយផ្តល់គ្រឿងលើកទឹកចិត្តដើម្បីធ្វើការស្រាវជ្រាវ និងស្វែងរកថវិកាពីស្ថាប័នជាតិ តំបន់ និងអន្តរជាតិសម្រាប់ធ្វើការស្រាវជ្រាវ។ |

| | |
|---|---|
| **៤.0** | **សហការស្រាវជ្រាវនិងសហប្រតិបត្តិការអន្តរជាតិ** |
| ៤.១ | ពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវរវាងអ្នកស្រាវជ្រាវ វិទ្យាស្ថានស្រាវជ្រាវនិងមជ្ឈមណ្ឌលស្រាវជ្រាវ គ្រប់វិស័យ ទាំងកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ។ |
| ៤.២ | ពង្រីកឱកាសជូនបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ដើម្បីចូលរួមក្នុងកម្មវិធីផ្លាស់ប្តូរនានាដូចជាការផ្តល់អាហារូបករណ៍ស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិត និងឱកាសអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗទៀត។ កិច្ចការនេះអាចពាក់ព័ន្ធនឹងការស្វែងរកកន្លែងសមស្របនៅតាមគ្រឹះស្ថានស្រាវជ្រាវនានាជាអន្តរជាតិសម្រាប់ដាក់បុគ្គលិករយៈពេលវែងឬខ្លី ឬធ្វើជាម្ចាស់ផ្ទះទទួលភ្ញៀវអ្នកស្រាវជ្រាវមកពី ក្រៅ។ |
| **៥.0** | **សេវាកម្មស្រាវជ្រាវនិងប្រឹក្សាយោបល់** |
| ៥.១ | បង្កើតក្រុមការងារសម្រាប់ដេញថ្លៃយកឱកាសប្រឹក្សាយោបល់និងមូលនិធិស្រាវជ្រាវនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក។ |
| ៥.២ | ប្រើប្រាស់សេវាស្រាវជ្រាវនិងប្រឹក្សាយោបល់ស.ភ.ភ.ព. ដើម្បីរួមចំណែកក្នុងការពង្រីកចំណេះដឹង ក្នុងការផ្តល់សេវាសហគមន៍ និងក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា។ |
| **៦.0** | **ការលើកទឹកចិត្តស្រាវជ្រាវតាមវិធីច្នៃប្រឌិត** |
| ៦.១ | បង្កើតឋានៈសម្រាប់អ្នកស្រាវជ្រាវស.ភ.ភ.ព. តាមបទពិសោធតិចឬច្រើន ដើម្បីទូទាត់សងពួកគាត់ដែលចំណាយពេលធ្វើការស្រាវជ្រាវនិងបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ក្រៅពីភារកិច្ចបង្រៀន។ |
| ៦.២ | ផ្តល់គ្រឿងលើកទឹកចិត្តដូចជា ថវិកា ប័ណ្ណសរសើរ ឬប័ណ្ណទទួលស្គាល់វិជ្ជាជីវៈ ដល់អ្នកមានស្នាដៃស្រាវជ្រាវល្អៗដូចជាការបោះពុម្ពផ្សាយនានា។ |
| ៦.៣ | ផ្សារភ្ជាប់ការតម្លើងឋានៈបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព.ទៅនឹងស្នាដៃស្រាវជ្រាវដោយបង្កើតលក្ខណៈវិនិច្ឆ័យដែលផ្អែកលើការអនុវត្តជាក់ស្តែងដូចជា ការបោះពុម្ពផ្សាយ និងការដកស្រង់ជាដើម។ |
| ៦.៤ | ឧបត្ថម្ភបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ដែលមានការទទួលស្គាល់ស្នាដៃស្រាវជ្រាវ ពីស្ថាប័នអន្តរជាតិ ដើម្បីបន្តការស្រាវជ្រាវរបស់ខ្លួនទៅមុខទៀត។ |
| **៧.0** | **ការបោះពុម្ពផ្សាយនិងការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ** |
| ៧.១ | ធ្វើទស្សនាវដ្តីស្រាវជ្រាវអន្តរវិស័យដែលមានការត្រួតពិនិត្យពីអ្នកវិទ្យាសាស្ត្រដើម្បីចែករំលែកស្នាដៃស្រាវជ្រាវក្នុងប្រទេស ក្នុងតំបន់ និងក្នុងពិភពលោក តាមរយៈការបោះពុម្ព និងតាមប្រព័ន្ធអេឡិចត្រូនិច។ |

| | |
|---|---|
| ៧.២ | ជំរុញបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ឱ្យបោះពុម្ពស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្ដីកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ ដែលមានសន្ទស្សន៍ដកស្រង់ ( Citation Indices ) ស្ថិតក្នុងចំណាត់ថ្នាក់ខ្ពស់។ |
| ៧.៣ | លើកកម្ពស់ការប្រើប្រាស់លទ្ធផលស្រាវជ្រាវស.ភ.ភ.ព. ក្នុងការធ្វើផែនការ ធ្វើគោលនយោបាយ ដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ធ្វើបឋកថាសាធារណៈ និងក្នុងការធ្វើគម្រោងអភិវឌ្ឍន៍ ដើម្បីទាញយកប្រយោជន៍ពីការច្នៃប្រឌិតនិងនវានុវត្តន៍របស់អ្នកស្រាវជ្រាវ។ ស្នាដៃស្រាវជ្រាវដែលបានបោះពុម្ពត្រូវតែមានក្នុងបណ្ណាល័យស.ភ.ភ.ព. និងការិយាល័យស្រាវជ្រាវ សម្រាប់បុគ្គលិកអប់រំនិងនិស្សិតទាំងអស់ប្រើប្រាស់។ |
| ៧.៤ | រៀបចំវេទិកាប្រចាំឆ្នាំដើម្បីពិភាក្សាលើលទ្ធផលស្រាវជ្រាវ ក្នុងគោលបំណងបង្ហាញពីផលប្រយោជន៍នៃរបកគំហើញទាំងនោះក្នុងការបង្កើតគោលនយោបាយ និងក្នុងការអនុវត្តជាក់ស្ដែងផ្សេងទៀត។ |
| **៨.០** | **បង្កើនការគាំទ្រដល់ការស្រាវជ្រាវពង្រីកចំណេះដឹងនិងការស្រាវជ្រាវអនុវត្ត** |
| ៨.១ | បង្កើនលទ្ធភាពប្រើប្រាស់មូលដ្ឋានទិន្នន័យដែលពេញនិយមដូចជា ScienceDirect, Taylor និង Francis, Springer និង Sage សម្រាប់ជូនបុគ្គលិកស្រាវជ្រាវនិងនិស្សិត។ |
| ៨.២ | បណ្ណាល័យស.ភ.ភ.ព. ត្រូវមានធនធានគ្រប់គ្រាន់ដើម្បីបង្កជួយសម្រួលដល់បុគ្គលិកស្រាវជ្រាវ និស្សិត និងបញ្ញវន្តមកពីក្រៅប្រទេសឱ្យធ្វើការស្រាវជ្រាវប្រកបដោយគុណភាព។ |
| ៨.៣ | ធ្វើឱ្យគ្រឿងបរិក្ខាទាំងឡាយនៅស.ភ.ភ.ព. មានភាពប្រសើរឡើង ដើម្បីជួយសម្រួលឱ្យការស្រាវជ្រាវទទួលបានលទ្ធផលប្រកបដោយគុណភាពខ្ពស់។ |
| ៨.៤ | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីជួយសម្រួលដល់ការស្រាវជ្រាវតាមឯកទេសផ្សេងៗក្នុងវិស័យ STEM និងវិទ្យាសាស្ត្រសង្គម ដោយមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយវិស័យឧស្សាហកម្ម។ |
| **៩.០** | **ការផ្ដល់មូលនិធិស្រាវជ្រាវ** |
| ៩.១ | បែងចែកថវិកាពី ៥%ទៅ១០% នៃប្រាក់ចំណូលសុទ្ធរបស់សាកលវិទ្យាល័យសម្រាប់ជំរុញសកម្មភាពស្រាវជ្រាវដូចជាហិរញ្ញប្បទានស្រាវជ្រាវសម្រាប់បុគ្គលិកអប់រំស.ភ.ភ.ព. ការធ្វើទស្សនាវដ្ដីស្រាវជ្រាវ និងប្រតិបត្តិការសារព័ត៌មានស.ភ.ភ.ព. ជាដើម។ |
| ៩.២ | ស្នើសុំក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានថវិកាជាតិប្រចាំឆ្នាំសម្រាប់ប្រើប្រាស់ដើម្បីពង្រឹងវប្បធម៌ស្រាវជ្រាវនៅស.ភ.ភ.ព.។ |

| | |
|---|---|
| **១០.០** | **ការសម្របសម្រួលការស្រាវជ្រាវ** |
| ១០.១ | បង្កើតប្រព័ន្ធចុះបញ្ជីច្រកចេញចូលតែមួយសម្រាប់សកម្មភាពស្រាវជ្រាវនានា ដែលអនុវត្តដោយបុគ្គលិកអប់រំស.ភ.ភ.ព. ដើម្បីជួយសម្រួលដល់ការិយាល័យស្រាវជ្រាវក្នុងការតាមដានលទ្ធផលស្រាវជ្រាវ។ |
| ១០.២ | ពង្រឹងសមត្ថភាពការិយាល័យស្រាវជ្រាវក្នុងការគ្រប់គ្រងនិងសម្របសម្រួលសកម្មភាពនានាដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ។ ការិយាល័យស្រាវជ្រាវគឺជាលេខាធិការដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រស្រាវជ្រាវស.ភ.ភ.ព. និងជួយជ្រោមជ្រែងគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ។ |

# ជំពូក ២ គុណភាពស្រាវជ្រាវនិងកម្មសិទ្ធបញ្ញា

## ២.១. ស្នាដៃស្រាវជ្រាវ ផលប្រយោជន៍នៃស្នាដៃស្រាវជ្រាវ និងផលជះនៃស្នាដៃស្រាវជ្រាវ

ការិយាល័យស្រាវជ្រាវត្រូវធ្វើការជាមួយដេប៉ាតឺម៉ង់និងមហាវិទ្យាល័យនីមួយៗ ក្នុងការពិនិត្យគម្រោងស្រាវជ្រាវនានាដើម្បីឱ្យដឹងថា តើគម្រោងទាំងនោះមានប្រយោជន៍ និងមានឥទ្ធិពលលើដំណោះស្រាយបញ្ហាសង្គមដូចក្នុងគំនូសបំព្រួញខាងក្រោមនេះដែរឬទេ។




ប្រព័ន្ធបណ្ណសារស្រាវជ្រាវឌីជីថលមួយនឹងត្រូវបានបង្កើតឡើងដើម្បីជួយដល់ការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ និងលើកស្ទួយផលប្រយោជន៍ និងផលជះនៃស្នាដៃស្រាវជ្រាវរបស់បុគ្គលិកអប់រំស.ភ.ភ.ព. ឱ្យកាន់តែទូលំទូលាយ។ ស្នាដៃស្រាវជ្រាវទាំងផ្នែកចំណេះដឹងនិងទាំងផ្នែកអនុវត្តនឹងត្រូវបានបោះពុម្ពទុកក្នុងប័ណ្ណសារនោះ ដែលជាកន្លែងរក្សាឯកសារស្រាវជ្រាវអនឡាញ ដើម្បីបង្កភាពងាយស្រួលដល់បុគ្គលិកអប់រំស.ភ.ភ.ព. ក្នុងការចែករំលែកការស្រាវជ្រាវរបស់ខ្លួនសម្រាប់កិច្ចសហការអន្តរជាតិជាមួយស្ថាប័នដទៃ។ ឯកសារស្រាវជ្រាវអនឡាញមានដូចជាសៀវភៅ ជំពូកសៀវភៅ ឯកសារសម្រាប់ពិភាក្សា អត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្ដី អត្ថបទបោះពុម្ពផ្សាយក្នុងសន្និសីទ ឯកសារបច្ចេកទេស និងរបាយការណ៍ផ្សេងៗទៀត។ ការិយាល័យស្រាវជ្រាវនឹងគ្រប់គ្រងកម្មសិទ្ធិបញ្ញារបស់បុគ្គលិកស្រាវជ្រាវ ដោយធានាថា នៅពេលដែលស្នាដៃរបស់ពួកគេត្រូវបានរក្សាទុកក្នុងប័ណ្ណសារនោះ ការរក្សាសិទ្ធិតឹងរឹងចំពោះស្នាដៃនីមួយៗនឹងត្រូវបានគាំទ្រ។ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវស.ភ.ភ.ព. ត្រូវជួយបុគ្គលិកស្រាវជ្រាវក្នុងការចរចាអំពីបញ្ហាទាំងនេះ។

ការិយាល័យស្រាវជ្រាវនឹងប្រើប្រាស់បណ្ណសារតម្កល់ឯកសារស្រាវជ្រាវអនឡាញនេះដើម្បីវាយតម្លៃស្នាដៃស្រាវជ្រាវ ផលប្រយោជន៍នៃស្នាដៃស្រាវជ្រាវ និងផលជះនៃស្នាដៃស្រាវជ្រាវរបស់បុគ្គលិកស្រាវជ្រាវស.ភ.ភ.ព.។ ក្រៅពីផលប្រយោជន៍នៃស្នាដៃស្រាវជ្រាវប្រកបដោយស្តង់ដារដូចជា ការបោះពុម្ពអត្ថបទទស្សនាវដ្តីស្រាវជ្រាវនិងសៀវភៅ ប្រព័ន្ធនេះនឹងវាយតម្លៃស្នាដៃច្នៃប្រឌិតនានា វីដេអូ ប្លក់ និងប្រព័ន្ធផ្សព្វផ្សាយដ៏ទៃទៀត ព្រមទាំងការស្រាវជ្រាវផ្នែកអនុវត្តដូចជារបាយការណ៍បច្ចេកទេស និងសេចក្តីសង្ខេបគោលនយោបាយជាដើម។ ចំនួននៃការដាក់សំណើគម្រោងស្រាវជ្រាវហើយទទួលបានហិរញ្ញប្បទានស្រាវជ្រាវដោយជោគជ័យ និងបរិមាណប្រាក់ចំណូលដែលទទួលបាន ក៏នឹងត្រូវបានរាប់បញ្ចូលក្នុងការវាយតម្លៃបែបបរិមាណវិស័យផងដែរ។ ការិយាល័យស្រាវជ្រាវត្រូវប្រើប្រាស់ទិន្នន័យក្នុងបណ្ណសារនេះ ក្នុងការវាយតម្លៃប្រចាំត្រីមាសដើម្បីផ្តល់ក្រេឌីតនិងអត្ថប្រយោជន៍ជូនអ្នកស្រាវជ្រាវដែលមានស្នាដៃល្អ។ អត្ថប្រយោជន៍ទាំងនេះអាចមានដូចជា ការតម្លើងឋានៈសាស្ត្រាចារ្យ ថវិកា ការផ្តល់វិញ្ញាបនប័ត្រកិត្តិយស ឬប័ណ្ណសរសើរផ្សេងៗ។

## ២.២. គុណភាពនៃការស្រាវជ្រាវ

ការិយាល័យស្រាវជ្រាវត្រូវធ្វើការជាមួយផ្នែកនិងមហាវិទ្យាល័យនីមួយៗ ដើម្បីធ្វើចំណាត់ថ្នាក់និងកំណត់គុណភាពទស្សនាវដ្តីស្រាវជ្រាវតាមវិស័យនីមួយៗផ្សេងៗគ្នា ដោយផ្អែកលើសន្ទស្សន៍ដកស្រង់ (Citation Index) ដែលមានការទទួលស្គាល់ក្នុងប្រទេស ក្នុងតំបន់ និងជាអន្តរជាតិដូចជា ISI, Scopus និងសន្ទស្សន៍ដកស្រង់ដទៃទៀត។ គុណភាពនៃស្នាដៃស្រាវជ្រាវត្រូវបានវាយតម្លៃដោយសន្ទស្សន៍ដកស្រង់នីមួយៗតាមវិធីផ្សេងគ្នា។ ឧទាហរណ៍៖

- **The Institute for Scientific Information (ISI)** គឺជាវិទ្យាស្ថានបម្រើសេវាកម្មបោះពុម្ពផ្សាយអត្ថបទសិក្សាស្រាវជ្រាវ នៅទីក្រុង Philadelphia ដែលត្រូវបានបង្កើតឡើងដំបូងគេដោយអ្នកវិទ្យាសាស្ត្រមួយរូបឈ្មោះ Eugene Garfield នៅទសវត្សឆ្នាំ១៩៦០។ វិទ្យាស្ថាននេះផ្តល់នូវសេវាកម្មផ្សេងៗទាក់ទងនឹងមូលដ្ឋានទិន្នន័យវិទ្យាសាស្ត្រនិងគន្ថនិទ្ទេស ដែលមានជំនាញក្នុងការធ្វើលិបិក្រមនិងការវិភាគសន្ទស្សន៍ដកស្រង់ (Citation Index)។ បញ្ជីទស្សនាវដ្តីស្រាវជ្រាវជាង ១៨០០០ក្បាល ត្រូវបានវិទ្យាស្ថាននេះរក្សាទុក ក្នុងនោះ មានផ្នែកសង្គមសាស្ត្រនិងមនុស្សសាស្ត្រប្រហែល១១០០ចំណងជើង។ បញ្ជីនេះអាចរកបានតាមគេហទំព័រ http://mjl.clarivate.com។
- **The Science Citation Index（SCI）** ក៏ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃ **ISI** ដោយ Dr. Eugene Garfield ដែរ។ ចាប់តាំងពីឆ្នាំ១៩៩០ SCI បានពង្រីកកាន់តែធំ ហើយមកទល់ពេលនេះ រក្សាទុកជាង ៨៥០០ទស្សនាវដ្តី ទាក់ទងនឹង១៥០មុខវិជ្ជា ដែលអ្នកស្រាវជ្រាវអាចរក

បានតាមរូបភាពច្រើនយ៉ាងដូចជា Web of Science and SciSearch ជាដើម។ ស្នាដៃស្រាវជ្រាវមួយចំនួនតូចដែលត្រូវបានវាយតម្លៃដោយ SCI ក៏មានការផ្សព្វផ្សាយដោយបោះពុម្ពជា CD និងជាទស្សនាវដ្ដីផងដែរ។ មូលដ្ឋានទិន្នន័យ SCI នេះមានភាពងាយស្រួលដល់អ្នកស្រាវជ្រាវ ក្នុងការតាមដានអត្ថបទដែលបានដកស្រង់ពីស្នាដៃមុនៗរបស់ខ្លួន ហើយថែមទាំងអាចកំណត់បាននូវស្នាដៃដែលត្រូវបានគេដកស្រង់ច្រើនបំផុតក្នុងវិស័យឬប្រធានបទណាមួយទៀតផង។ បញ្ជីទស្សនាវដ្ដីដែលគ្រប់គ្រងដោយSCIអាចរកបានតាមគេហទំព័រ https://www.scijournal.org។

- **Scopus** គឺជាមូលដ្ឋានទិន្នន័យនៃសង្ខិត្តន័យ (Abstaract) និងការដកស្រង់ (Citation) ដែលត្រូវបានបង្កើតឡើងដោយ Elsevier ក្នុងឆ្នាំ២០០៤។ មូលដ្ឋានទិន្នន័យនេះមានស្នាដៃចំនួន ៣៦៣៧៧ចំណងជើង (ចំណងជើងសកម្ម ២២.៧៩៤ និងអសកម្ម ១៣.៥៨៣) ដែលបានពីក្រុមហ៊ុនបោះពុម្ពផ្សាយចំនួន១១៦៧៨។ **Scopus** ជាមូលដ្ឋានទិន្នន័យដែលផ្ទុកអត្ថបទស្រាវជ្រាវគុណភាពខ្ពស់តាមមុខវិជ្ជានីមួយៗ ហើយមានទស្សនាវដ្ដីដែលបានពិនិត្យយ៉ាងហ្មត់ចត់ពីក្រុមអ្នកវិទ្យាសាស្ត្រ ចំនួន៣៤៣៤៦។ ប្រភពបីប្រភេទគឺ ស៊េរីសៀវភៅ ទស្សនាវដ្ដី និងទស្សនាវដ្ដីពាណិជ្ជកម្ម ត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំ ដើម្បីរក្សាស្តង់ដារគុណភាពខ្ពស់។ Scopus មានរង្វាស់គុណភាពបួនយ៉ាង សម្រាប់វាយតម្លៃទស្សនាវដ្ដីនីមួយៗគឺ h-Index, CiteScore, SCImago Journal Rank (SJR) និង Source Normalized Impact per Paper (SNIP)។ បញ្ជីទស្សនាវដ្ដីដែលគ្រប់គ្រងដោយ Scopus អាចរកបានតាមគេហទំព័រ https://www.scopus.com។
- **The Emerging Sources Citation Index** (**ESCI**) គឺជាមូលដ្ឋានទិន្នន័យថ្មីមួយនៅក្នុង Web of Science ដែលបានចាប់ផ្ដើមនៅចុងឆ្នាំ២០១៥។ ពេលចាប់ផ្ដើមដំបូង ESCI មានទស្សនាវដ្ដីប្រហែល៣០០០ ទាក់ទងនឹងគ្រប់មុខវិជ្ជា។ ទស្សនាវដ្ដីមួយត្រូវទទួលបានជ្រើសរើសពី ESCI ជាមុនសិន ទើបអាចដាក់ពាក្យសុំចុះក្នុងបញ្ជីបណ្ដាញសន្ទស្សន៍វិទ្យាសាស្ត្រ (Web of Science indexes) ដទៃទៀត ដូចជា SCI, SSCI, និង AHCI (the Arts and Humanities Citation Index) ជាដើម។ ទស្សនាវដ្ដី ដែលបានដាក់ស្នើសុំវាយតម្លៃចូលក្នុង Web of Science databases ធំៗទាំងនេះ ត្រូវបានទទួលចុះក្នុងបញ្ជី ESCI ដោយឆ្លងកាត់ការត្រួតពិនិត្យគុណភាព និងកែលម្អកាន់តែស៊ីជម្រៅ។ បញ្ជីទស្សនាវដ្ដីនៅ ESCI អាចរកបានតាមគេហទំព័រ http://mjl.clarivate.com/cgi-bin/jrnlst/jlresults.cgi ។
- **Accredited international citations** ទទួលបានពីទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រ ដែលមានគ្រប់មុខវិជ្ជានិងមានជាច្រើនភាសាដែលត្រូវបានគ្រប់គ្រងដើម្បីគុណភាពដោយផ្អែកលើសន្ទស្សន៍ដកស្រង់ទាំងនេះ។ ទស្សនាវដ្ដីនីមួយៗត្រូវបានចាត់ថ្នាក់ដោយផ្អែកលើចំនួននៃការដកស្រង់ (Number of Citations) ដែលបង្ហាញពីកត្តាផលជះថា តើការស្រាវជ្រាវនេះមានឥទ្ធិពលយ៉ាង

ណា។ **Accredited international citations** មាននៅក្នុងមូលដ្ឋានទិន្នន័យមួយចំនួនដូចជា the Bibliography of Asian Studies; the International Bibliography of the Social Sciences; International Political Science Abstracts; the Public Affairs Information Service; the Centre for Agriculture and Bioscience International (CABI) and NHN។ ដោយសារពុំមានសន្ទស្សន៍ជាក់លាក់ណាមួយអាចបញ្ជាក់បានថា សេចក្តីដកស្រង់នៃស្នាដៃស្រាវជ្រាវមួយត្រូវបានទទួល accredited international citation គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវស.ភ.ភ.ព. នឹងវាយតម្លៃគុណភាពស្រាវជ្រាវដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានពីប្រភពដែលមាន។

- **National and regional citation indices** គឺជាមូលដ្ឋានទិន្នន័យដែលបង្កើតឡើងដើម្បីធ្វើសន្ទស្សន៍កំណត់ត្រាគន្ថនិទ្ទេសនិងការដកស្រង់លើស្នាដៃស្រាវជ្រាវដែលមានគុណភាពក្នុងទស្សនាវដ្តីស្រាវជ្រាវនៅកម្ពុជានិងបណ្តាប្រទេសអាស៊ានដទៃទៀត។ ទស្សនាវដ្តីទាំងនេះមានបោះពុម្ពផ្សាយជាច្រើននៅប្រទេសប្រ៊ុយណេដារូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ ដោយសារពុំមានសន្ទស្សន៍ជាក់លាក់ណាមួយបញ្ជាក់ថា ស្នាដៃស្រាវជ្រាវមួយទទួលបានការដកស្រង់ថ្នាក់ជាតិឬថ្នាក់តំបន់ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ ស.ភ.ភ.ព. នឹងវាយតម្លៃគុណភាពនៃស្នាដៃស្រាវជ្រាវដោយផ្អែកលើប្រភពដែលមាន។
- **Open access journals** គឺជាស្ថាប័នដែលគាំទ្រខ្លួនឯងនិងមិនទទួលថវិកាពីស្ថាប័នខាងក្រៅឬរដ្ឋាភិបាលឡើយ។ ស្ថាប័នទស្សនាវដ្តីទាំងនេះដំណើរការបានដោយទទួលថវិកាពីការបង់ថ្លៃរបស់អ្នកនិពន្ធតែម្យ៉ាងគត់។ ស្ថាប័នទស្សនាវដ្តីប្រភេទនេះមិនទទួលបានកម្រៃពីការជាវទស្សនាវដ្តីទេ ព្រោះអ្នកសិក្សាស្រាវជ្រាវអាចចូលប្រើប្រាស់តាមអ៊ីនធឺណែតបានដោយសេរី។ ជាទូទៅ អ្នកនិពន្ធត្រូវបង់ថ្លៃសម្រាប់ចាត់ចែងកិច្ចការនានាដែលពាក់ព័ន្ធនឹងការបោះពុម្ព បន្ទាប់ពីសំណៅដើមរបស់ខ្លួនត្រូវបានទទួលយកសម្រាប់ការបោះពុម្ពផ្សាយ។ ដោយសារមិនមានប្រភពជាក់លាក់ណាមួយបញ្ជាក់ថា អត្ថបទក្នុងទស្សនាវដ្តីត្រូវបានធ្វើសន្ទស្សន៍ដកស្រង់ដោយស្ថាប័ននេះ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវស.ភ.ភ.ព. នឹងវាយតម្លៃស្នាដៃស្រាវជ្រាវដោយផ្អែកលើប្រភពដែលមាន។

បន្ទាប់ពីអត្ថបទស្រាវជ្រាវត្រូវបានដាក់ជូនពិនិត្យសម្រាប់ការបោះពុម្ពផ្សាយ ការវាយតម្លៃគុណភាពនឹងត្រូវបានធ្វើភ្លាមៗ ដោយមានសេចក្តីបញ្ជាក់ថា អត្ថបទស្រាវជ្រាវនេះមានគុណភាពដល់កម្រិតអាចឬមិនអាចបោះពុម្ពផ្សាយបាន។ ផលជះនៃស្នាដៃស្រាវជ្រាវនឹងត្រូវបានវាស់វែងដោយការរាប់ចំនួន

ដកស្រង់, the h-index និងកត្តាផលជះនានានៃទស្សនាវដ្តី។ សន្ទស្សន៍ដកស្រង់របស់ Google នឹងត្រូវបានច្នៃជាឧបករណ៍ប្រើប្រាស់ដើម្បីដឹងពីស្ថានភាពអំណាននិងចំនួនដកស្រង់នៃស្នាដៃស្រាវជ្រាវរបស់បុគ្គលិកស្រាវជ្រាវស.ភ.ភ.ព.។ ការិយាល័យស្រាវជ្រាវត្រូវធ្វើការជាមួយបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ដើម្បីបង្កើតគណនី Google citation ផ្ទាល់ខ្លួន ដែលនឹងត្រូវតភ្ជាប់ទៅនឹងប័ណ្ណសារស.ភ.ភ.ព. ដែលជាកន្លែងរក្សាទុកឯកសារស្រាវជ្រាវអនឡាញ។

## ២.៣. កម្មសិទ្ធបញ្ញា

ការការពារកម្មសិទ្ធិបញ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងការធានាគុណភាពនៃសកម្មភាពបង្រៀននិងស្រាវជ្រាវនៅស.ភ.ភ.ព.។ ក្នុងគោលនយោបាយនេះ កម្មសិទ្ធិបញ្ញាសំដៅទៅលើភាពជាម្ចាស់នៃលទ្ធផលស្រាវជ្រាវដែលផលិតបានក្នុងក្របខណ្ឌសាកលវិទ្យាល័យ និងរបកគំហើញរបស់ភាគីទីបីដែលអ្នកស្រាវជ្រាវដ៏ទៃទៀតបានប្រើប្រាស់ក្នុងស្នាដៃរបស់គេ។ ឯកសារទាំងនេះអាចយកចេញពីការស្រាវជ្រាវផ្នែកចំណេះដឹងឬផ្នែកអនុវត្ត និងអាចមានដូចជាការបង្កើតថ្មី ការបោះពុម្ពផ្សាយ ស្នាដៃស្រាវជ្រាវ មូលដ្ឋានទិន្នន័យ ពូជរុក្ខជាតិថ្មីៗ អម្បូរសត្វល្អិត ឬទស្សនទាននិងទ្រឹស្តីថ្មីៗ។ សិទ្ធិនៃកម្មសិទ្ធិបញ្ញាចំពោះលទ្ធផលស្រាវជ្រាវត្រូវបានការពារ ដើម្បីធានាថា គំនិតនៃទស្សនទាន ឬគំរូពិសោធ (laboratory-scale prototypes) ដែលទាមទារការស្រាវជ្រាវនិងការអភិវឌ្ឍបន្ថែមទៀតសិន មុននឹងធ្វើអាជីវកម្ម អាចផ្តល់ផលប្រយោជន៍ទាំងអ្នកស្រាវជ្រាវ ទាំងសាកលវិទ្យាល័យ។ ការផ្តល់ជូនស.ភ.ភ.ព. នូវសិទ្ធិក្នុងការទទួលបានកម្មសិទ្ធិបញ្ញា ដែលកើតចេញពីការស្រាវជ្រាវដែលប្រើប្រាស់ហិរញ្ញប្បទានរដ្ឋ អាចជួយឱ្យគ្រឹះស្ថាននេះធ្វើអាជីវកម្មលើការស្រាវជ្រាវ និងអាចជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការពន្លឿនការផ្លាស់ប្តូរការបង្កើតថ្មីទៅក្នុងដំណើរការនិងផលិតផលឧស្សាហកម្ម ព្រមទាំងពង្រឹងកិច្ចសហការជិតស្និតរវាងសាកលវិទ្យាល័យនិងឧស្សាហកម្មផងដែរ។

សកម្មភាពបង្រៀននៅស.ភ.ភ.ព. ក៏នាំឱ្យមានការផលិតកម្មសិទ្ធិបញ្ញាដែរដូចជា ឯកសារបោះពុម្ព កម្មវិធីព័ត៌មានវិទ្យា (Software) ភាពយន្ត ឯកសារថតជាសំឡេង បទបង្ហាញគ្រប់ប្រភេទ (Multimedia Presentations)។ កម្មសិទ្ធិបញ្ញានេះក៏តម្រូវឱ្យមានការការពារដោយមានការរក្សាសិទ្ធិអ្នកនិពន្ធផងដែរ។ អ៊ិនធើណែតនិងបច្ចេកវិទ្យាឯទៀតសម្រាប់ការចែករំលែកព័ត៌មានបានបង្កើនការទទួលបានឯកសារសិក្សាយ៉ាងច្រើន ប៉ុន្តែក៏បង្កឱ្យមានជម្លោះកាន់តែខ្លាំងលើការប្រើប្រាស់និងភាពជាម្ចាស់លើឯកសារនេះ។ ដូច្នេះ ក្នុងគោលនយោបាយនេះ កម្មសិទ្ធិបញ្ញាក៏សំដៅទៅលើភាពជាម្ចាស់នៃឯកសារបង្រៀនគ្រប់ប្រភេទ ការទទួលបានឯកសារសិក្សា និងការប្រើប្រាស់ឯកសាររបស់ភាគីទីបីផងដែរ។ ស.ភ.ភ.ព. មានបំណងបម្រើផលប្រយោជន៍សាធារណៈដោយចែកចាយចំណេះដឹងនិងជំនាញតាមរយៈការស្រាវជ្រាវនិងការបង្រៀន។ ក្នុងន័យនេះ ទន្ទឹមនឹងធ្វើឱ្យលទ្ធផលនៃសកម្មភាពទាំងនេះ

អាចផ្សព្វផ្សាយបានជាសាធារណៈ ស.ភ.ភ.ព. ខិតខំកសាងទំនាក់ទំនងរឹងមាំជាមួយវិស័យឯកជន។ ជាទូទៅ ឯកសារទាំងនេះនឹងមានលក្ខណៈសមរម្យសម្រាប់ការបោះពុម្ពផ្សាយដែលបើកឱ្យប្រើប្រាស់ដោយចំហ។ ប៉ុន្តែទោះយ៉ាងនេះក្តី របកគំហើញមួយចំនួននឹងត្រូវរក្សាជាសម្ងាត់ក្នុងរយៈពេលសមស្របមួយ ដើម្បីឱ្យរបកគំហើញទាំងនោះអាចត្រូវបានធ្វើអាជីវកម្មផង។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងបង្កើតគោលការណ៍ណែនាំច្បាស់លាស់ស្តីពីការគ្រប់គ្រងកម្មសិទ្ធិបញ្ញានៅស.ភ.ភ.ព.។

ការយកលទ្ធផលស្រាវជ្រាវទៅប្រើប្រាស់នៅដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍគឺជាកម្មវត្ថុសំខាន់របស់ស.ភ.ភ.ព.។ គោលនយោបាយស្តីពីកម្មសិទ្ធិបញ្ញាគឺជាតម្រូវការចាំបាច់សម្រាប់កិច្ចសហប្រតិបត្តិការប្រកបដោយជោគជ័យរវាងអ្នកស្រាវជ្រាវនិងដៃគូពាណិជ្ជកម្ម។ ឯកសារផ្លូវការមួយនឹងត្រូវបានបង្កើតឡើងដើម្បីគូសបញ្ជាក់អំពី៖

- សិទ្ធិទទួលបានកម្មសិទ្ធិបញ្ញាដោយអ្នកស្រាវជ្រាវនិងដៃគូពាណិជ្ជកម្ម
- នីតិវិធីសម្រាប់កំណត់អត្តសញ្ញាណ វាយតម្លៃ ការពារ និងគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- នីតិវិធីសម្រាប់កិច្ចសហប្រតិបត្តិការជាមួយភាគីទីបី
- គោលការណ៍ណែនាំស្តីពីការចែករំលែកអត្ថប្រយោជន៍ពីការធ្វើអាជីវកម្មប្រកបដោយជោគជ័យលើរបកគំហើញនៃការស្រាវជ្រាវ និង
- យន្តការផ្ទៃក្នុងដើម្បីធានាឱ្យមានការគោរពសិទ្ធិកម្មសិទ្ធិបញ្ញា។

ឯកសារនេះនឹងផ្តល់ជូនអ្នកពាក់ព័ន្ធនូវការណែនាំច្បាស់លាស់អំពីគោលនយោបាយរបស់ស.ភ.ភ.ព. ក្នុងការគ្រប់គ្រងកម្មសិទ្ធិបញ្ញា។ អ្នកពាក់ព័ន្ធសំខាន់ៗរួមមានអ្នកស្រាវជ្រាវ អ្នកបច្ចេកទេស និងនិស្សិត ព្រមទាំងដៃគូអាជីវកម្ម ដូចជា អ្នកឧបត្ថម្ភការស្រាវជ្រាវផ្នែកឧស្សាហកម្ម អ្នកប្រឹក្សាយោបល់ អង្គការមិនស្វែងរកប្រាក់ចំណេញ សហគ្រាសធុនតូចនិងមធ្យម និងស្ថាប័នរដ្ឋ។ ការស្រាវជ្រាវដែលធ្វើឡើងដោយបុគ្គលិកអប់រំស.ភ.ភ.ព. ឬអ្នកស្រាវជ្រាវមកពីក្រៅប្រទេសដែលសម្របសម្រួលដោយ ស.ភ.ភ.ព. ត្រូវស្ថិតក្រោមលក្ខខណ្ឌដូចតទៅនេះ៖

- ការបោះពុម្ពផ្សាយឬប៉ាតង់ ដែលជាស្នាដៃរបស់បុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ត្រូវធ្វើឡើងដោយមានឈ្មោះ ស.ភ.ភ.ព. ផងដែរ។
- ការបោះពុម្ពផ្សាយឬប៉ាតង់ដែលជាស្នាដៃរបស់និស្សិតក្រោមការជួយជ្រោមជ្រែងរបស់ស.ភ.ភ.ព. ត្រូវធ្វើឡើងដោយមានឈ្មោះ ស.ភ.ភ.ព. ផងដែរ។
- ការបោះពុម្ពផ្សាយឬប៉ាតង់ដែលផលិតដោយអ្នកស្រាវជ្រាវមកពីក្រៅប្រទេស ដែលស.ភ.ភ.ព. ទទួលឱ្យមកធ្វើការស្រាវជ្រាវ ត្រូវធ្វើឡើងដោយមានឈ្មោះ ស.ភ.ភ.ព. ផងដែរ។

បុគ្គលិកអប់រំនិងនិស្សិតស.ភ.ភ.ព. អ្នកស្រាវជ្រាវមកពីក្រៅប្រទេស និងសហការីពីខាងក្រៅ សុទ្ធតែចូលរួមក្នុងការបង្កើតកម្មសិទ្ធិបញ្ញានៅពេលធ្វើសកម្មភាពបង្រៀននិងស្រាវជ្រាវ។ កម្មសិទ្ធិបញ្ញានេះអាចមានទម្រង់ជាព័ត៌មានបច្ចេកទេសសំងាត់ អាថ៌កំបាំងពាណិជ្ជកម្មរបស់បង្កើតថ្មីដែលមានប៉ាតង់ ម៉ូដ ឬប្លង់ ឬគម្រោងបង្កើតថ្មី កម្មវិធីព័ត៌មានវិទ្យា ស្នាដៃសំណេរគំនូរបច្ចេកទេស (diagrams) ឬឯកសារបង្រៀន និងបទបង្ហាញនានា ដែលជាលទ្ធផលនៃការខិតខំបង្កើតថ្មី។ កិច្ចព្រមព្រៀងនានាលើកម្មសិទ្ធិបញ្ញានឹងត្រូវបានបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណែកក្នុងការបង្កើតនិងផ្សព្វផ្សាយរបស់ច្នៃប្រឌិត របស់បង្កើតថ្មី របកគំហើញស្រាវជ្រាវ សម្ភារៈបង្រៀន ឬចំណាប់អារម្មណ៍ និងការរំពឹងទុកតិចតួចក៏ដោយ។ អ្នកពាក់ព័ន្ធទាំងនេះអាចមានដូចជា គណៈគ្រប់គ្រងសាកលវិទ្យាល័យ និយោជិត ក្រុមស្រាវជ្រាវ និស្សិតថ្នាក់ក្រោយបរិញ្ញបត្រនិងក្រោយបណ្ឌិត អ្នកស្រាវជ្រាវមកពីក្រៅប្រទេស អ្នកឧបត្ថម្ភស្រាវជ្រាវ និងអ្នកសហការស្រាវជ្រាវវិស័យឧស្សាហកម្ម ការិយាល័យប៉ាតង់ជាតិ ស្ថាប័នផ្តល់មូលនិធិ និងរដ្ឋាភិបាល។

# ជំពូក ៣ ការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវ កម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រនិងក្រោយបណ្ឌិត

## ៣.១. ប្រភេទហិរញ្ញប្បទាន

សាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តគម្រោងស្រាវជ្រាវទាំងឡាយដោយប្រើថវិកាផ្ទាល់ខ្លួន និងទទួលយកជំនួយអភិវឌ្ឍសម្រាប់ធ្វើសកម្មភាពនានាទាក់ទងនឹងការស្រាវជ្រាវ។ នីតិវិធីគ្រប់គ្រងជំនួយស្រាវជ្រាវជួយធានាចំពោះម្ចាស់ជំនួយថា សកម្មភាពស្រាវជ្រាវនឹងត្រូវធ្វើឡើងស្របតាមវិសាលភាពការងារ ហើយការចំណាយនឹងមានភាពត្រឹមត្រូវតាមគោលការណ៍និងលក្ខខណ្ឌរបស់ជំនួយដែលត្រូវគ្នានឹងគោលនយោបាយស.ភ.ភ.ព.។ មន្ត្រីការិយាល័យស្រាវជ្រាវម្នាក់នឹងធ្វើជាជនបង្គោលក្នុងការធានាទទួលខុសត្រូវចំពោះអ្នកពាក់ព័ន្ធសំខាន់ៗថា ការរំពឹងទុករបស់ពួកគេនឹងត្រូវបានបំពេញតាំងពីចំណុចចាប់ផ្តើមដល់ចុងបញ្ចប់នៃគម្រោង។

ថវិកាគម្រោងត្រូវបានគ្រប់គ្រងដោយប្រើប្រាស់ក្របខ័ណ្ឌការងារនេះដើម្បីកាត់បន្ថយហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុនិងការខូចកេរ្តិ៍ឈ្មោះ ស.ភ.ភ.ព. តាមរយៈសកម្មភាពស្រាវជ្រាវផ្សេងៗ។ ការគូសបញ្ជាក់នូវទំនួលខុសត្រូវសំខាន់ៗធានានូវតម្លាភាពនិងគណនេយ្យភាពក្នុងការការប្រើប្រាស់មូលនិធិស្រាវជ្រាវ ចំណាត់ការលើថវិកាមិនចំណាយ ការចំណាយលើសកំណត់ និងថ្លៃចំណាយទៀងទាត់នានា (overheads)។ ហិរញ្ញប្បទានស្រាវជ្រាវនៅស.ភ.ភ.ព. ត្រូវបានបែងចែកជាបួនប្រភេទ៖

- **ហិរញ្ញប្បទានស្រាវជ្រាវស.ភ.ភ.ព.** សំដៅលើថវិកាសម្រាប់វិនិយោគលើសកម្មភាពនានាដែលទាក់ទងនឹងការស្រាវជ្រាវ ដើម្បីកសាងសមត្ថភាពជូនបុគ្គលិកស្រាវជ្រាវក្នុងការស្រាវជ្រាវប្រកបដោយគុណភាពនិងធ្វើការបោះពុម្ពផ្សាយ។ ភាគច្រើននៃថវិកានេះបានពីថ្លៃសិក្សា និងប្រភពចំណូលផ្សេងទៀតរបស់ស.ភ.ភ.ព.។ ថវិកានេះប្រើប្រាស់សម្រាប់ការស្រាវជ្រាវនិងការចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និសីទនានាដែលបង្កើនសមត្ថភាពបុគ្គលិកស្រាវជ្រាវក្នុងការបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវអន្តរជាតិ។
- **ជំនួយស្រាវជ្រាវនិងប្រាក់កម្ចី** សំដៅលើថវិកាស្រាវជ្រាវដែលផ្តល់ដោយក្រសួងអប់រំយុវជន និងកីឡា ស្ថាប័នរដ្ឋដទៃទៀត និងដៃគូអភិវឌ្ឍនានាដូចជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍអាស៊ីជាដើម ដើម្បីលើកកម្ពស់វប្បធម៌ស្រាវជ្រាវនៅស.ភ.ភ.ព.។ ស.ភ.ភ.ព. គ្រប់គ្រងជំនួយដោយផ្ទាល់ស្របតាមគោលនយោបាយរបស់ខ្លួន។ ថវិកានេះត្រូវបានផ្តល់ជូនជាជំនួយចំពោះស្ថាប័នជាជាងចំពោះបុគ្គល។
- **ហិរញ្ញប្បទាននិងអាហារូបករណ៍ស្រាវជ្រាវ** សំដៅលើហិរញ្ញប្បទាននិងកញ្ចប់ថវិកានានាដែលផ្តល់ដោយអង្គការជាតិឬអន្តរជាតិ ដើម្បីផ្តល់ថវិកាដល់គម្រោងស្រាវជ្រាវដែលអនុវត្តដោយបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. រៀងៗខ្លួនតែម្តង។ អ្នកស្រាវជ្រាវនៅស.ភ.ភ.ព. អាចដាក់ពាក្យសុំ

ហិរញ្ញប្បទានស្រាវជ្រាវឬអាហារូបករណ៍ស្រាវជ្រាវខាងក្រៅ និងគ្រប់គ្រងហិរញ្ញប្បទាននោះដោយខ្លួនឯង ប្រសិនបើប្រើប្រាស់គណនីផ្ទាល់ខ្លួន។

## ៣.២. សេវាផ្តល់ប្រឹក្សាយោបល់

សេវាផ្តល់ប្រឹក្សាយោបល់ សំដៅលើសេវាដែលអ្នកជំនាញស្រាវជ្រាវស.ភ.ភ.ព. អាចផ្តល់ការប្រឹក្សាយោបល់ជូនអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នជាតិ ឬអន្តរជាតិ ក្នុងការអនុវត្តគម្រោងស្រាវជ្រាវណាមួយជាលក្ខណៈបុគ្គលរៀងៗខ្លួន ដោយស្ថិតឬមិនស្ថិតក្រោមការគ្រប់គ្រងរបស់ស.ភ.ភ.ព. ក៏បាន។

## ៣.៣. ការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវ ស.ភ.ភ.ព.

ហិរញ្ញប្បទានស្រាវជ្រាវស.ភ.ភ.ព. ត្រូវបានបែងចែកជារៀងរាល់ឆ្នាំតាមការយល់ព្រមពីក្រុមប្រឹក្សាសាកលវិទ្យាល័យ។ រីឯជំនួយស្រាវជ្រាវនិងប្រាក់កម្ចីដែលផ្តល់ជូនស.ភ.ភ.ព. ត្រូវតែអនុវត្តតាមបទប្បញ្ញត្តិរបស់ស.ភ.ភ.ព. និងរបស់ដៃគូស្រាវជ្រាវ។ ការចំណាយលើគម្រោងស្រាវជ្រាវទាំងពីរប្រភេទនេះនឹងត្រូវបែងចែកដូចខាងក្រោម៖

- ៥០% សម្រាប់ថ្លៃប្រតិបត្តិការ
- ៤០% ត្រូវផ្តល់ជូនបុគ្គលិកដែលពាក់ព័ន្ធដើម្បីលើកទឹកចិត្តដល់ការធ្វើសកម្មភាពស្រាវជ្រាវ និង
- ១០% សម្រាប់របស់ប្រើប្រាស់និងកម្មវិធីព័ត៌មានវិទ្យាដែលត្រូវការចាំបាច់។

អ្នកដែលទទួលហិរញ្ញប្បទាននីមួយៗត្រូវផ្តល់ជូនជាបីដំណាក់កាលគឺ៖ លើកទី១ ៣០% នៃថវិកាសរុប លើកទី២ ៥០% និង លើកទី៣ ២០%។ ការិយាល័យស្រាវជ្រាវនិងការិយាល័យគណនេយ្យសហការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវស.ភ.ភ.ព.។ បន្ទាប់ពីត្រូវបានជ្រើសរើសហើយ អ្នកទទួលហិរញ្ញប្បទានស្រាវជ្រាវអាចដកថវិកាដំណាក់កាលដំបូងដើម្បីចុះប្រមូលទិន្នន័យ ឬធ្វើពិសោធន៍ផ្សេងៗ។ ការដកថវិកាលើកទី២ នឹងអាចធ្វើបានបន្ទាប់ពីផ្តល់របាយការណ៍វឌ្ឍនភាពដ៏សមស្រមមួយដែលអាចទទួលយកបានដោយការិយាល័យស្រាវជ្រាវនិងការិយាល័យគណនេយ្យ។ ការិយាល័យស្រាវជ្រាវជួយជ្រោមជ្រែងនិងត្រួតពិនិត្យផ្នែកគុណភាពនិងបច្ចេកទេសស្រាវជ្រាវរបស់អ្នកទទួលហិរញ្ញប្បទានម្នាក់ៗ។ រីឯការិយាល័យគណនេយ្យជួយជ្រោមជ្រែងនិងត្រួតពិនិត្យឯកសារហិរញ្ញវត្ថុសម្រាប់ការទូទាត់និងការធ្វើសវនកម្ម។ ដើម្បីទទួលបានថវិកាដំណាក់កាលចុងក្រោយ អ្នកទទួលហិរញ្ញប្បទានត្រូវបញ្ជូនរបាយការណ៍និទានកថាចុងក្រោយ ឬសំណៅដើមដែលត្រូវបានទទួលយកសម្រាប់បោះពុម្ពផ្សាយក្នុងទស្សនាវដ្តីកម្រិតជាតិក្តី កម្រិតតំបន់ក្តី ឬកម្រិតអន្តរជាតិក្តី។

រីឯជំនួយស្រាវជ្រាវនិងប្រាក់កម្ចីត្រូវបានគ្រប់គ្រងដោយអ្នកស្រាវជ្រាវ ឬដេប៉ាតឺម៉ង់រៀងៗខ្លួន។

បុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យសុំហិរញ្ញប្បទាននិងអាហារូបករណ៍ស្រាវជ្រាវ និងការប្រឹក្សាយោបល់ ទោះក្នុងនាមជាផ្នែកមួយនៃស្ថាប័នក្តី ឬក្នុងនាមជាបុគ្គលអ្នកស្រាវជ្រាវរៀងៗខ្លួនក្តី។ ស.ភ.ភ.ព. នឹងចេញលិខិតគាំទ្រតាមការស្នើសុំធ្វើការស្រាវជ្រាវ និងផ្តល់ការគាំទ្រដើម្បីជួយពួកគាត់ឱ្យទទួលបានមូលនិធិ។ អ្នកដាក់ពាក្យសុំដែលទទួលបានហិរញ្ញប្បទានស្រាវជ្រាវត្រូវបង់វិភាគទានជូនសាកលវិទ្យាល័យ ដោយមិនគិតពីទំហំនៃជំនួយនោះទេ។ ថ្លៃសេវានេះនឹងស្ថិតនៅចន្លោះពី ៥% ទៅ ១០% នៃថវិកាសរុបដែលទទួលបានពីទីស្ថាប័នផ្តល់មូលនិធិ។ ដើម្បីឱ្យមានតម្លាភាព ស.ភ.ភ.ព. នឹងអនុញ្ញាតឱ្យដៃគូស្រាវជ្រាវធ្វើសវនកម្មពីខាងក្រៅលើការចំណាយរបស់គម្រោងតាមការស្នើសុំ។

ការគ្រប់គ្រងថវិកាគម្រោងស្រាវជ្រាវត្រូវអនុវត្តតាមបទប្បញ្ញត្តិហិរញ្ញវត្ថុស.ភ.ភ.ព.។ រាល់ថវិកាគម្រោង ដែលទទួលបានដោយមានការគាំទ្រពីស.ភ.ភ.ព. ត្រូវតែផ្ទេរចូលគណនីស.ភ.ភ.ព. ដែលបានកំណត់ទុក ហើយការដកថវិកាយកទៅប្រើប្រាស់ក្នុងគម្រោងត្រូវគោរពតាមនីតិវិធីហិរញ្ញវត្ថុរបស់ស.ភ.ភ.ព.។ អ្នកទទួលហិរញ្ញប្បទានស្រាវជ្រាវក៏ត្រូវបានស្នើឱ្យដាក់ជូនការិយាល័យស្រាវជ្រាវនូវសេចក្តីសង្ខេបនៃសំណើស្រាវជ្រាវផងដែរ។

## ៣.៤. តួនាទីនិងទំនួលខុសត្រូវ

ការិយាល័យស្រាវជ្រាវតាមដាន សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេសដល់គម្រោងស្រាវជ្រាវទាំងអស់ ចំណែកការិយាល័យគណនេយ្យធានាភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ។ ការិយាល័យស្រាវជ្រាវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យលទ្ធផលលទ្ធផលនិងផលប៉ះពាល់នៃគម្រោងស្រាវជ្រាវនីមួយៗ។ ការទទួលខុសត្រូវទាំងនេះមានចែងដូចខាងក្រោម៖

### ៣.៤.១. ការិយាល័យស្រាវជ្រាវ

- ពិនិត្យនិងអនុម័តរាល់អនុស្សរណៈនៃការយោគយល់គ្នាជាមួយដៃគូអភិវឌ្ឍន៍ទាក់ទងនឹងគម្រោងស្រាវជ្រាវនានា។
- វាយតម្លៃពីផលប៉ះពាល់នៃការស្រាវជ្រាវដែលបានស្នើឡើង ដើម្បីធានាថា ការស្រាវជ្រាវនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងប្រធានបទស្រាវជ្រាវគោលជាយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ។
- ជួយស.ភ.ភ.ព. ក្នុងការបង្កើតប្រាក់ចំណូលបន្ថែមសម្រាប់គម្រោងស្រាវជ្រាវនានាដែលមានផលប្រយោជន៍ដល់សង្គមកម្ពុជា។

- ធានាថា កិច្ចសន្យាស្រាវជ្រាវមានភាពត្រឹមត្រូវតាមគោលការណ៍ច្បាប់ ក្រមសីលធម៌និងគោលនយោបាយរបស់ស.ភ.ភ.ព.។
- តាមដានសកម្មភាពស្រាវជ្រាវ និងចរចាដោយផ្ទាល់ជាមួយដៃគូស្រាវជ្រាវទាក់ទងនឹងការកែប្រែចំណុចសំខាន់ៗក្នុងកិច្ចព្រមព្រៀងផ្តល់មូលនិធិ ដោយពិគ្រោះយោបល់ជាមួយក្រុមស្រាវជ្រាវ។
- ពិនិត្យរាល់ការកែប្រែកិច្ចព្រមព្រៀងភាពជាដៃគូ ដើម្បីឱ្យប្រាកដថា វិសាលភាពនិងលក្ខខណ្ឌការងារអាចទទួលយកបានសម្រាប់ដៃគូស្រាវជ្រាវផង និងស្របតាមគោលនយោបាយនានារបស់ស.ភ.ភ.ព. ផង។
- ជួយបុគ្គលិកស្រាវជ្រាវ ឬដេប៉ាតឺម៉ង់នីមួយៗក្នុងការបកស្រាយអំពីគោលនយោបាយរបស់ដៃគូស្រាវជ្រាវ សាកលវិទ្យាល័យ និងរដ្ឋាភិបាល ទាក់ទងនឹងលក្ខខណ្ឌនៃការផ្តល់ថវិកានីមួយៗ អំពីរបៀបអនុវត្តគម្រោង និងអំពីការចែកចាយនិងរាយការណ៍អំពីលទ្ធផលស្រាវជ្រាវ។

### ៣.៤.២. ការិយាល័យគណនេយ្យ

- ផ្តល់លទ្ធភាពទទួលបានមូលនិធិស្រាវជ្រាវជូនអ្នកទទួលជំនួយដើម្បីបានធ្វើសកម្មភាពស្រាវជ្រាវឱ្យទាន់ពេលវេលា។
- ត្រួតពិនិត្យនិងធានាភាពត្រឹមត្រូវនៃការអនុវត្តនីតិវិធីចំណាយគម្រោងស្រាវជ្រាវនិងឯកសារហិរញ្ញវត្ថុសម្រាប់ការធ្វើសវនកម្ម។
- ជួយមន្ត្រីហិរញ្ញវត្ថុក្នុងគម្រោងដើម្បីឆ្លើយសំណួរអ្នកធ្វើសវនកម្ម។
- កត់ចំណាំគម្រោងនានាដែលមិនទាន់បានផ្តល់ប័ណ្ណចំណាយជូនទៅដៃគូអភិវឌ្ឍន៍។
- បញ្ឈប់សកម្មភាពគណនីគម្រោងដែលបានបញ្ចប់ និងផ្ទេរទឹកប្រាក់ដែលនៅសល់ទៅតាមកិច្ចព្រមព្រៀងផ្តល់មូលនិធិ។

## ៣.៥. កម្មវិធីស្រាវជ្រាវរបស់និស្សិត

ដើម្បីលើកស្ទួយគុណភាពស្រាវជ្រាវនិងបង្កើនចំនួននៃការបោះពុម្ពផ្សាយនិងការដកស្រង់ស្នាដៃស្រាវជ្រាវ កម្មវិធីជ្រើសរើសនិស្សិតស.ភ.ភ.ព. ថ្នាក់បរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានសមត្ថភាពខ្ពស់ឱ្យធ្វើការស្រាវជ្រាវថ្នាក់បណ្ឌិត នឹងត្រូវបានរៀបចំឡើង។ អ្នកដែលទើបទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតថ្មីៗក៏នឹងមានឱកាសទទួលបានមូលនិធិសម្រាប់ការស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតទៀតផងដែរ។ និស្សិតថ្នាក់បរិញ្ញាបត្រឬក្រោយបរិញ្ញាបត្រអាចត្រូវបានសាស្ត្រាចារ្យឬដេប៉ាតឺម៉ង់ពាក់ព័ន្ធអនុញ្ញាតឱ្យចូលរួមក្នុងកម្មវិធីស្រាវជ្រាវស.ភ.ភ.ព.។ ព្រឹទ្ធបុរសឬប្រធានដេប៉ាតឺម៉ង់ពាក់ព័ន្ធមានភារកិច្ចនិងទំនួលខុសត្រូវចំពោះការងារនេះ។

បេក្ខជនដែលត្រូវបានជ្រើសរើសចូលកម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រនិងក្រោយបណ្ឌិតនឹងបញ្ចប់ការសិក្សាសរសេរនិក្ខេបបទនិងបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវណាមួយដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រ។ លក្ខខណ្ឌស្តីពីចំនួនបោះពុម្ព សន្ទស្សន៍គុណភាព និងការដកស្រង់សម្រាប់កម្មវិធីនីមួយៗត្រូវកំណត់ដោយដេប៉ាតឺម៉ង់ឬមហាវិទ្យាល័យពាក់ព័ន្ធ។ និស្សិតថ្នាក់បរិញ្ញាបត្រ ដែលត្រូវបានកំណត់ថាសមស្របសម្រាប់ជ្រើសរើសចូលក្នុងកម្មវិធីស្រាវជ្រាវក្រោយបរិញ្ញាបត្រ នឹងតម្រូវឱ្យលើកគម្រោងស្រាវជ្រាវមួយ ដែលផ្នែកនៃគម្រោងនេះអាចអភិវឌ្ឍឱ្យទៅជានិក្ខេបបទបញ្ចប់ការសិក្សា និងបញ្ជូនសំណៅស្នាដៃស្រាវជ្រាវទៅកាន់ទស្សនាវដ្ដីស្រាវជ្រាវណាមួយដែលមានការពិនិត្យពីអ្នកវិទ្យាសាស្ត្រដើម្បីស្នើសុំបោះពុម្ព។ និស្សិតថ្នាក់បរិញ្ញាបត្រ ដែលមានស្នាដៃស្រាវជ្រាវបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រ នឹងទទួលបានអាហារូបករណ៍ពេញលេញសម្រាប់កម្មវិធីស្រាវជ្រាវក្រោយបរិញ្ញាបត្រ។ ស.ភ.ភ.ព. ទទួលឱ្យចូលក្នុងកម្មវិធីស្រាវជ្រាវតែនិស្សិតដែល៖

- បានបញ្ចប់ការស្រាវជ្រាវដែលមានគុណភាពខ្ពស់ក្នុងវិស័យសិក្សាដែលពាក់ព័ន្ធ។
- មានសាស្ត្រាចារ្យណែនាំដែលមានបំណិននិងចំណេះដឹងចាំបាច់សម្រាប់ការចរចាបញ្ចប់កម្មវិធីស្រាវជ្រាវដោយជោគជ័យ។
- មានការធានាថា និស្សិតមានលទ្ធភាពប្រើប្រាស់សម្ភារៈនិងឧបករណ៍ដែលចាំបាច់ក្នុងការបញ្ចប់កម្មវិធីស្រាវជ្រាវដោយជោគជ័យ។
- បានបង្ហាញពីការតាំងចិត្តខ្ពស់ក្នុងការសរសេរអត្ថបទស្រាវជ្រាវដែលមានគុណភាពគ្រប់គ្រាន់ដើម្បីបោះពុម្ពក្នុងទស្សនាវដ្ដីដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រ និងមានការគាំទ្រពីសាស្ត្រាចារ្យណែនាំ។

## ៣.៦. កម្មវិធីក្រោយបណ្ឌិត

អ្នកដែលត្រូវបានតែងតាំងចូលក្នុងកម្មវិធីក្រោយបណ្ឌិតត្រូវរួមចំណែកដល់សហគមន៍វិទ្យាសាស្ត្រក្នុងការលើកកម្ពស់កម្មវិធីស្រាវជ្រាវនិងអប់រំរបស់ស.ភ.ភ.ព.។ កម្មវិធីនេះនាំមកនូវចំណេះដឹងក្នុងជំនាញ ការយល់ដឹង ការច្នៃប្រឌិត និងនវានុវត្តន៍ ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ការស្រាវជ្រាវនិងអប់រំរបស់សហគមន៍ស្រាវជ្រាវស.ភ.ភ.ព.។ ដើម្បីសម្រេចកិច្ចការនេះ សាកលវិទ្យាល័យខិតខំផ្តល់បទពិសោធន៍ល្អៗដែលគួរឱ្យចាប់អារម្មណ៍និងមានប្រយោជន៍សម្រាប់អ្នកដែលត្រូវបានតែងតាំងចូលក្នុងកម្មវិធីក្រោយបណ្ឌិត ដោយសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តរួមគ្នារវាងសាកលវិទ្យាល័យ មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងបញ្ញវន្តខ្លួនឯងផ្ទាល់។ អង្គភាពកិច្ចការកម្មវិធីក្រោយបណ្ឌិតនឹងត្រូវបានបង្កើតឡើងដោយសាលាក្រោយបរិញ្ញាបត្រស.ភ.ភ.ព. ដើម្បីគ្រប់គ្រងកម្មវិធីក្រោយបណ្ឌិត និងធ្វើការយ៉ាងសកម្មដើម្បីធានាភាព

ត្រឹមត្រូវតាមគោលនយោបាយសម្រាប់កម្មវិធីក្រោយបណ្ឌិត។ ស.ភ.ភ.ព. នឹងតែងតាំងអ្នកស្រាវជ្រាវចូលក្នុងកម្មវិធីក្រោយបណ្ឌិតតាមតំណែងពីរប្រភេទដូចខាងក្រោម៖

១. តំណែងដែលចុះកិច្ចសន្យាផ្តោតខ្លាំងតែលើការស្រាវជ្រាវ និង

២. តំណែងដែលចុះកិច្ចសន្យាបង្រៀនផងនិងស្រាវជ្រាវផង។

បុគ្គលម្នាក់ៗ ដែលបានតែងតាំងចូលតំណែងនីមួយៗ ត្រូវធ្វើការពេញម៉ោង និងមិនឱ្យលើសពី៣ឆ្នាំ។ ជារៀងរាល់ឆ្នាំ លទ្ធផលការងារនិងវឌ្ឍនភាពរបស់អ្នកស្រាវជ្រាវក្នុងតំណែងនីមួយៗនឹងត្រូវបានត្រួតពិនិត្យដោយអង្គភាពកិច្ចការកម្មវិធីក្រោយបណ្ឌិត ដើម្បីពិចារណាបន្តឬបញ្ឈប់តំណែងណាមួយ។ លក្ខណៈសម្បត្តិនិងទំនួលខុសត្រូវនៃអ្នកស្រាវជ្រាវក្នុងកម្មវិធីក្រោយបណ្ឌិតស.ភ.ភ.ព. មានដូចខាងក្រោម៖

- អ្នកស្រាវជ្រាវក្នុងតំណែងជា Postdoctoral Associate ត្រូវបញ្ចប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ ចំណែកអ្នកស្រាវជ្រាវក្នុងតំណែងជា Postdoctoral Fellow ត្រូវបញ្ចប់ថ្នាក់បណ្ឌិតដោយជោគជ័យ ក្នុងវិស័យដែលទាក់ទងនឹងការទទួលខុសត្រូវខ្លួន មិនលើសពីប្រាំឆ្នាំកន្លងមក។
- ចំពោះអ្នកស្រាវជ្រាវដែលស្ថិតក្នុងមុខដំណែងទី១ ក៏អាចតម្រូវឱ្យជួយបង្រៀន រហូតដល់៥០%នៃពេលវេលារបស់គាត់ តាមការចាំបាច់ផងដែរ។ និង
- កម្មវិធីនេះត្រូវបានគេមើលឃើញថា ជាដំណាក់កាលត្រៀមសម្រាប់អាជីពពេញម៉ោងក្នុងការបង្រៀននិងស្រាវជ្រាវ ក្នុងវិស័យឧស្សាហកម្ម ក្នុងការងាររដ្ឋាភិបាល ឬក្នុងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

ជាទូទៅ តំណែងទាំងពីរនេះទទួលមូលនិធិពីម្ចាស់ជំនួយដែលប្រគល់ឱ្យស.ភ.ភ.ព. ចាត់ចែង ហើយអ្នកស្រាវជ្រាវដែលត្រូវបានផ្តល់តំណែងណាមួយ ត្រូវបានចាត់ទុកជាបុគ្គលិកស.ភ.ភ.ព. ដោយទទួលបានប្រាក់បៀវត្សសម្រាប់ការងារដែលបានធ្វើ។ អ្នកស្រាវជ្រាវក្នុងកម្មវិធីក្រោយបណ្ឌិតត្រូវបានចាត់ទុកថា ស្ថិតក្នុងវគ្គបណ្តុះបណ្តាលការងារ ព្រោះពួកគាត់ធ្វើការក្នុងគម្រោងស្រាវជ្រាវដែលទទួលបានប្រាក់ឧបត្ថម្ភ។ កម្មវិធីនេះអាចជួយស.ភ.ភ.ព.ក្នុងការផ្តល់នូវអត្ថប្រយោជន៍និងសេវាកម្មចាំបាច់នានាដល់អ្នកពាក់ព័ន្ធសំខាន់ៗ។ តំណែងស្រាវជ្រាវនិងបង្រៀនមានទំនួលខុសត្រូវជាចម្បងក្នុងការបង្រៀន។

តំណែងអ្នកស្រាវជ្រាវក្រោយបណ្ឌិតត្រូវមានសាស្ត្រាចារ្យណែនាំម្នាក់ក្នុងដេប៉ាតឺម៉ង់ពាក់ព័ន្ធ។ ទំនួលខុសត្រូវរបស់សាស្ត្រាចារ្យណែនាំគឺ៖ (១) ណែនាំ តាមដាន និងជម្រុញការងារអ្នកស្រាវជ្រាវដែលស្ថិតក្រោមការណែនាំរបស់ខ្លួន (២) ជូនអ្នកនោះនូវលិខិតដែលរៀបរាប់ពីភារកិច្ចរបស់គាត់ គោល

បំណង កម្មវត្ថុ និងលទ្ធផលរំពឹងទុកនៃកម្មវិធី (៣) ទាក់ទងអ្នកស្រាវជ្រាវឱ្យបានទៀងទាត់ (៤) ផ្តល់ការវាយតម្លៃការអនុវត្តឱ្យបានទាន់ពេលវេលា យ៉ាងហោចណាស់មួយឆ្នាំម្តង និង (៥) ផ្តល់អនុសាសន៍ក្នុងអាជីព និងជួយឱ្យមានលទ្ធភាពទទួលបានការងារ។ កម្មវិធីក្រោយបណ្ឌិតនេះនឹងត្រូវបានកែលម្អតាមការចាំបាច់។

# ជំពូក ៤ តំណែងស្រាវជ្រាវ និងកម្មវិធីលើកទឹកចិត្តអ្នកស្រាវជ្រាវ

## ៤.១. តំណែងស្រាវជ្រាវ

ដើម្បីលើកកម្ពស់វប្បធម៌ស្រាវជ្រាវសម្រាប់បោះពុម្ពផ្សាយ សាកលវិទ្យាល័យត្រូវកំណត់តំណែងស្រាវជ្រាវជាអាទិភាពចំនួនពីរគឺៈ តំណែងអ្នកស្រាវជ្រាវបទពិសោធតិច និងតំណែងអ្នកស្រាវជ្រាវបទពិសោធច្រើន។ មានតែបុគ្គលិកស្រាវជ្រាវស.ភ.ភ.ព. ប៉ុណ្ណោះ ដែលអាចមានសិទ្ធិដាក់ពាក្យសុំចូលរួមប្រកួតប្រជែងយកតំណែងស្រាវជ្រាវណាមួយ។ អ្នកដែលត្រូវបានជ្រើសរើសនឹងទទួលបានប្រាក់លើកទឹកចិត្តបន្ថែមជារៀងរាល់ខែពីស.ភ.ភ.ព.។ នៅពេលទទួលបានប្រាក់ឧបត្ថម្ភនេះ បុគ្គលិកស្រាវជ្រាវនឹងត្រូវបានតម្រូវឱ្យកាត់បន្ថយចំនួនម៉ោងបង្រៀន និងផ្តោតលើសកម្មភាពស្រាវជ្រាវ។ ការជ្រើសរើសយកអ្នកស្រាវជ្រាវចូលកាន់តំណែងស្រាវជ្រាវនីមួយៗនឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំដោយគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

**សម្រាប់តំណែងអ្នកស្រាវជ្រាវបទពិសោធតិច បេក្ខជនត្រូវមានៈ**

- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬបណ្ឌិតមួយពីសាកលវិទ្យាល័យល្បីៗ។
- សមត្ថភាពប្រមូលទិន្នន័យ វិភាគទិន្នន័យ និងសរសេរការស្រាវជ្រាវផ្អែកទ្រឹស្តីសម្រាប់ការបោះពុម្ពផ្សាយ។
- ការបោះពុម្ពផ្សាយយ៉ាងទូលំទូលាយក្នុងទស្សនាវដ្តីដែលបានពិនិត្យដោយអ្នកវិទ្យាសាស្ត្រ ក្នុងបណ្តាញទស្សនាវដ្តីថ្នាក់ជាតិនិងថ្នាក់តំបន់ដូចជា ASEAN citation index ជាដើម។

**សម្រាប់តំណែងអ្នកស្រាវជ្រាវបទពិសោធច្រើន បេក្ខជនត្រូវមានៈ**

- ទទួលបានបណ្ឌិតពីសាកលវិទ្យាល័យល្បីៗ។
- មានសមត្ថភាពប្រមូលទិន្នន័យ វិភាគទិន្នន័យ និងសរសេរការស្រាវជ្រាវផ្អែកទ្រឹស្តីសម្រាប់ការបោះពុម្ពផ្សាយ។
- មានការបោះពុម្ពផ្សាយយ៉ាងទូលំទូលាយក្នុងទស្សនាវដ្តីដែលបានពិនិត្យដោយអ្នកវិទ្យាសាស្ត្រ ក្នុងបណ្តាញទស្សនាវដ្តីអន្តរជាតិ ដូចជា SCI, ISI, និង Scopus ជាដើម។

អ្នកដែលស្ថិតក្នុងតំណែងអ្នកស្រាវជ្រាវបទពិសោធតិចនឹងត្រូវបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវយ៉ាងតិចមួយ ក្នុងទស្សនាវដ្តីដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រថ្នាក់ជាតិឬថ្នាក់តំបន់ ក្នុងរយៈពេល២ឆ្នាំ។ រីឯអ្នកដែលមានតំណែងអ្នកស្រាវជ្រាវបទពិសោធច្រើននឹងត្រូវបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវយ៉ាងតិចមួយក្នុងទស្សនាវដ្តីអន្តរជាតិដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រ ក្នុងរយៈពេល២ឆ្នាំដូចគ្នាដែរ។ ការ

តែងតាំងបុគ្គលិកស្រាវជ្រាវចូលកាន់តំណែងស្រាវជ្រាវត្រូវធ្វើជារៀងរាល់ឆ្នាំដោយមានកិច្ចសន្យាច្បាស់លាស់។ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនឹងពិនិត្យកិច្ចសន្យាទាំងនោះឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលឬវឌ្ឍនភាពការងារនិងលក្ខខណ្ឌបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ។ កិច្ចសន្យានឹងត្រូវបានបន្តចំពោះអ្នកស្រាវជ្រាវណាដែលពុំមានលទ្ធភាពបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។ កិច្ចសន្យានឹងត្រូវបានបញ្ចប់ចំពោះអ្នកស្រាវជ្រាវណាដែលពុំមានលទ្ធភាពបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។

## ៤.២. ការលើកទឹកចិត្ត

គោលដៅរួមនៃគោលនយោបាយនេះគឺដើម្បីលើកទឹកចិត្តបុគ្គលិកអប់រំស.ភ.ភ.ព. ឱ្យធ្វើការស្រាវជ្រាវ។ ប៉ុន្តែ បច្ចុប្បន្ននេះ បុគ្គលិកអប់រំស.ភ.ភ.ព. ត្រូវបានទាក់ទាញដោយសកម្មភាពបង្រៀនព្រោះពួកគាត់អាចទទួលបានប្រាក់ម៉ោងបន្ថែមពីសកម្មភាពបង្រៀននេះ។ ដូច្នេះ ដើម្បីអាចសម្រេចគោលដៅនេះបាន ការផ្តល់គ្រឿងលើកទឹកចិត្តជាថវិកានិងជាប័ណ្ណសរសើរគឺជាគន្លឹះសំខាន់។ ដើម្បីឱ្យសកម្មភាពស្រាវជ្រាវកាន់តែមានភាពទាក់ទាញ ការលើកទឹកចិត្តជាថវិកាត្រូវបានផ្តល់ជូនដោយផ្អែកលើចំនួនស្នាដៃបោះពុម្ពផ្សាយ និងគុណភាពដកស្រង់ដែលអ្នកស្រាវជ្រាវនីមួយៗសម្រេចបាន។ បុគ្គលិកស.ភ.ភ.ព. ដែលធ្វើការស្រាវជ្រាវដោយបានទទួលហិរញ្ញប្បទានស្រាវជ្រាវស.ភ.ភ.ព. ឬជំនួយស្រាវជ្រាវឬប្រាក់កម្ចី ហើយដែលស្នាដៃស្រាវជ្រាវរបស់គាត់ត្រូវបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវ នឹងអាចទទួលបានត្រឹមតែប័ណ្ណសរសើរប៉ុណ្ណោះ។ ប៉ុន្តែ អ្នកស្រាវជ្រាវដែលធ្វើការស្រាវជ្រាវដោយទទួលបានមូលនិធិពីប្រភពផ្សេងៗទៀត អាចនឹងទទួលបានគ្រឿងលើកទឹកចិត្តជាថវិកាផងនិងជាប័ណ្ណសរសើរផង។ ការលើកទឹកចិត្តទាំងនេះអាចត្រូវបានផ្តល់ជូនឱ្យអ្នកស្រាវជ្រាវដែលបានបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវដោយជោគជ័យ ហើយត្រូវបានគេដកស្រង់ជាហូរហែចេញពីសន្ទស្សន៍ដកស្រង់ដូចជា SCI, ISI, Scopus និងសន្ទស្សន៍ដកស្រង់អន្តរជាតិដទៃទៀត។ ការផ្តល់គ្រឿងលើកទឹកចិត្តទាំងនេះត្រូវចាប់អនុវត្តបន្ទាប់ពីគោលនយោបាយនេះត្រូវបានអនុម័ត។ លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់គ្រឿងលើកទឹកចិត្តដល់អ្នកដែលមានអត្ថបទស្រាវជ្រាវបោះពុម្ពក្នុងទស្សនាវដ្តីដែលពិនិត្យដោយអ្នកវិទ្យាសាស្ត្រពីររូបដែលមិនស្គាល់ម្ចាស់អត្ថបទ មានបង្ហាញក្នុងតារាងខាងក្រោមនេះ។

## តារាងទី១. លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់គ្រឿងលើកទឹកចិត្តជាប្រាក់និងប័ណ្ណសរសើរ

| លក្ខណៈវិនិច្ឆ័យ | សន្ទស្សន៍ | កម្រិតផលជះ |
|---|---|---|
| ១ | • Institute for Scientific Information (ISI)<br>• Science Citation Index (SCI)<br>• Scopus | កម្រិតផលជះ $\geq 1$ |
| ២ | • Institute for Scientific Information (ISI)<br>• Science Citation Index (SCI)<br>• Scopus<br>• Emerging Sources Citation Index (ESCI) | កម្រិតផលជះ $< 1$ |
| ៣ | • Accredited international citation indexes (i.e., ACI, ESCI, CAB Abstracts, Aqualine Abstracts, Cambridge Scientific Abstracts, Environment Abstracts, GEO Abstracts, IBZ/IBR, Science Citation Index and ICEA.) | មិនបាច់គិត |
| ៤ | Regional and national citation indexes (i.e., Google Scholar, EZB, and WorldCat) | មិនបាច់គិត |

- **ប្រភេទទី១**នឹងត្រូវបានផ្តល់ដោយសាកលវិទ្យាល័យសម្រាប់អត្ថបទដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី SCI ឬ ISI ឬ Scopus ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី១នេះនឹងទទួលបានការលើកទឹកចិត្តជាថវិកានិងប័ណ្ណសរសើរថ្នាក់លេខ១។
- **ប្រភេទទី២**នឹងត្រូវបានផ្តល់ដោយសាកលវិទ្យាល័យសម្រាប់អត្ថបទដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី SCI ឬ ISI ឬ Scopus ឬ ESCI ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី២នេះនឹងទទួលបានការលើកទឹកចិត្តជាថវិកានិងប័ណ្ណសរសើរថ្នាក់លេខ២។
- **ប្រភេទទី៣**នឹងត្រូវបានផ្តល់ដោយសាកលវិទ្យាល័យសម្រាប់អត្ថបទដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី ដែលមានសន្ទស្សន៍ដកស្រង់ត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដូចក្នុងតារាង

ខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី៣នេះនឹងទទួលបានការលើកទឹកចិត្តជាសាច់ប្រាក់និងប័ណ្ណសរសើរថ្នាក់លេខ៣។

- **ប្រភេទទី៤**នឹងត្រូវបានផ្តល់ដោយសាកលវិទ្យាល័យសម្រាប់អត្ថបទដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី ដែលមានសន្ទស្សន៍ដកស្រង់ថ្នាក់ជាតិនិងថ្នាក់តំបន់ ដូចក្នុងតារាងខាងលើ។ អ្នកស្រាវជ្រាវដែលមានលក្ខណៈវិនិច្ឆ័យប្រភេទទី៤នេះនឹងទទួលបានការលើកទឹកចិត្តជាសាច់ប្រាក់និងប័ណ្ណសរសើរថ្នាក់លេខ៤។